# សំណួរបួនប្រការ

## ដំណោះស្រាយវិបត្តិ
## នៃការរម្លូតកូនជាមួយនឹងជំណឿល្អនៃជីវិត



**និពន្ធដោយលោកគ្រូ ៖** ចន អ៊ែនសឺរ (ស្ថាបនិក និង ប្រធាន PassionLife Fellowship))។
**បកប្រែដោយលោកគ្រូ៖ ប៉ុក សុភាន**



## សំណួរបួនប្រការ

# ដំណោះស្រាយវិបត្តិនៃការរំលូតកូនជាមួយនឹងដំណឹងល្អនៃជីវិត

ការរំលូតកូន ជាការបញ្ចប់ជីវិតទារកដ៏មានតម្លៃយ៉ាងសាហាវរបស់មនុស្សលោកដែលនាំឲ្យស្ត្រីឈឺចុកចាប់ និង គ្រាំគ្រាចិត្ត។ ប៉ុន្តែការរំលូតកូន ជាសញ្ញាណនៃបញ្ហាស៊ីជម្រៅ និង តម្លៃដែលនៅក្នុងដួងចិត្ត និង គំនិតរបស់បុរសនិងស្ត្រី។

ដូច្នេះ តើយើងត្រូវផ្លាស់ប្តូរគំនិតនៃជម្រើសរំលូតកូននោះ ដោយរបៀបណា? តើសព្វថ្ងៃនេះ យើងត្រូវជួយអ្នកដែលស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់បែបនេះដូចម្តេច? តើយើងត្រូវនាំសេរីភាព និង ការប្រោសឲ្យជាពីការរំលូតកូនពីអតីកាល ហើយដែលជាប់ទាក់ទងនឹងអំពើបាបដោយរបៀប?

មេរៀននេះ នឹងជួយលោកអ្នក *យល់ដឹង* ទាក់ទងពីការរំលូតកូនតាមត្រសៃភ្នែករបស់ព្រះជាម្ចាស់ និងទទួលយករបៀបដែលព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងកែប្រែ ទាំងស្តាប់តាមការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដើម្បីឆ្លើយតបទៅនឹងការរំលូតកូន ហើយជួយសង្គ្រោះស្ត្រី និង ទារកក្នុងផ្ទៃក្នុងពេលមានផ្ទៃពោះដោយចៃដន្យ។

ដើម្បីឆ្លើយតបទៅបញ្ហានេះ សូមយើងបើកព្រះគម្ពីររបស់យើង ហើយពិនិត្យមើលសំណួរបួនប្រការដូចខាងក្រោម ៖

១-តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីខ្លះ អំពីជីវិតរបស់មនុស្សលោក រួមមានទាំងជីវិតនៅក្នុងផ្ទៃផង?
២-តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីខ្លះ អំពីការបង្ហូរឈាមជនស្លូតត្រង់ រួមមានទាំងការរំលូតកូនផង?
៣-តើយើងនាំព្រះគុណនៃដំណឹងល្អទៅដល់ពិរុទ្ធជននៃការរំលូតកូន ដើម្បីឲ្យគេបានទទួលការលើកលែងទោស និង មានសេរីភាព ដោយរបៀបណា?
៤-តើព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យធ្វើអ្វីខ្លះ ដើម្បីបញ្ឈប់ការបង្ហូរឈាមជនស្លូតត្រង់ ហើយតើត្រូវជួយមនុស្សដែលធ្វើដូច្នោះ ដោយរបៀបណា?

គ្រិស្តបរិស័ទចិន និង អ្នកជឿជាច្រើននៅជុំវិញពិភពលោក បានរៀន និងចែករំលែកមូលដ្ឋានគ្រឹះងាយយល់នៅក្នុងព្រះគម្ពីរ ទាក់ទងពីរបៀបបញ្ឈប់ការរំលូតកូន និងការនាំការប្រោសឲ្យជា និងមហន្តរាយនៃការរំលូតកូន។ ការសិក្សា និង ការចូលរួមជាមួយគ្រិស្តបរិស័ទនានាក្នុងពិភពលោកដើម្បីដំណោះស្រាយឆ្លើយតបទៅនឹងវិបត្តិនៃការរំលូតកូនជាមួយនឹងដំណឹងល្អ។

## សំណួរទី១ ៖ -តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីខ្លះ អំពីជីវិតរបស់មនុស្សលោក រួមមានទាំងជីវិតនៅក្នុងផ្ទៃផង ?

ការសិក្សាអំពីជីវិតមនុស្ស ជាដំបូងត្រូវមើលទៅលើចំណុចសំខាន់នៃជីវិត ហើយដែលថាព្រះជាម្ចាស់សព្វព្រះទ័យនឹងជីវិតជាជាងសេចក្តីស្លាប់។ យើងឃើញពីតម្លៃនៃជីវិតមនុស្ស និងរបៀបដែលត្រូវប្រព្រឹត្តចំពោះអ្នកដទៃ។ យើងមើលដោយសង្ខេបលើផែនការរបស់ព្រះជាម្ចាស់សម្រាប់បុត្រធិតា និង គ្រួសារ ហើយចុងបញ្ចប់ យើងនឹងកំណត់សញ្ញាណពីពេលវេលាដែលជីវិតមនុស្សចាប់ផ្តើមនៅក្នុងផ្ទៃ។

### តើព្រះគម្ពីរឲ្យនិយមន័យជីវិតយ៉ាងដូចម្តេច ?

*១-ព្រះជាម្ចាស់ ទ្រង់ជាជីវិត*

*«អ្នកណារកខ្ញុំឃើញ អ្នកនោះមានជីវិត..» (សុភាសិត ៨.៣៥)។*

«...ព្រះអង្គជាជីវិតរបស់អ្នក...» (ចោទិយកថា ៣០.២០)

*២-ព្រះជាម្ចាស់ ទ្រង់ប្រទានជីវិត*

«ព្រះអង្គក្ដាប់ព្រលឹងសត្វលោកទាំងអស់នៅក្នុងព្រះហស្ដរបស់ព្រះអង្គហើយដង្ហើមជីវិតរបស់មនុស្សក៏ស្ថិតនៅក្នុងព្រះហស្ដរបស់ព្រះអង្គដែរ»(យ៉ូប ១២.១០)។

*៣-ព្រះជាម្ចាស់ ទ្រង់ស្រឡាញ់ជីវិត*

-ទំនុកតម្កើង ៥៤.៤ បញ្ជាក់ថា ព្រះអង្គជាអ្នកការពារជីវិត ។

-ទំនុកតម្កើត ៧២.១៤ បញ្ជាក់ថា ព្រះអង្គជាអ្នករំដោះជីវិត ។

-ទំនុកតម្កើង ១២១.៧ បញ្ជាក់ ព្រះអង្គរក្សាជីវិត ។

*៤-ព្រះបុត្រារបស់ព្រះជាម្ចាស់ គឺព្រះយេស៊ូគ្រិស្ដ ទ្រង់ជាអំណោយនៃជីវិត*

-ព្រះយេស៊ូជាពន្លឺនៃជីវិត យោងតាមបទគម្ពីរយ៉ូហាន៨.១២។

-ព្រះយេស៊ូជាជីវិតដ៏ពេញបរិបូរ យោងតាមបទគម្ពីរយ៉ូហាន ១០.១០។

-ព្រះយេស៊ូជាជីវិតដ៏អស់កល្បជានិច្ច យោងតាមគម្ពីរយ៉ូហាន ៣.១៦។

ព្រះជាម្ចាស់ ជាជីវិត ហើយព្រះអំណោយរបស់ព្រះអង្គ គឺជាព្រះអំណោយទាននៃជីវិត។

*៥-ដំណឹងល្អពីព្រះគ្រិស្ដ ជាដំណឹងល្អនៃជីវិត*

-ចំពោះអ្នកវិនាស យើងជាក្លិននៃសេចក្ដីស្លាប់ដែលនាំឲ្យគេស្លាប់ ចំពោះអ្នកដែលបានទទួលការសង្គ្រោះ យើងជាក្លិននៃជីវិត ដែលនាំឲ្យគេមានជីវិត (២កូរិនថូស ២.១៦)។

## តើព្រះជាម្ចាស់ផ្ដល់តម្លៃអ្វីថ្លៃជាងគេ នៅក្នុងស្នាព្រះហស្ដទាំងអស់របស់ព្រះអង្គ?

មនុស្សលោកជាស្នាព្រះហស្ដដែលព្រះជាម្ចាស់រីករាយខ្លាំងបំផុត។ ជីវិតមនុស្សលោកជាម្កុដនៃការបង្កើតរបស់ព្រះជាម្ចាស់។ គម្ពីរទំនុកតម្កើង ៨.៣-៥ ចែងថា ៖ «[៣] ពេលទូលបង្គំសម្លឹងមើលផ្ទៃមេឃ ដែលជាស្នាព្រះហស្ដរបស់ព្រះអង្គ ហើយសម្លឹងមើលព្រះច័ន្ទ និងហ្វូងតារាដែលព្រះអង្គដាក់នៅលើមេឃនោះ [៤] ទូលបង្គំសួរខ្លួនឯងថា តើមនុស្សមានឋានៈអ្វីបានជាព្រះអង្គនឹកគិតដល់គេដូច្នេះ តើបុត្រមនុស្សជាអ្វីបានជាព្រះអង្គយកព្រះហឫទ័យទុកដាក់នឹងគេយ៉ាងនេះ?[៥] ព្រះអង្គបានធ្វើឲ្យគេមានឋានៈទាបជាងទេវតាតែបន្តិចប៉ុណ្ណោះព្រះអង្គប្រទានសិរីរុងរឿង និងកិត្តិយសដល់គេទុកជាមកុដរាជ្យ»។

## តើអ្វីដែលធ្វើឲ្យជីវិតមនុស្សលោកមានតម្លៃ?

ជីវិតមនុស្សលោកមានតម្លៃ ក៏ព្រោះតែព្រះជាម្ចាស់បានបង្កើតគេមកឲ្យលក្ខណៈដូចរូបអង្គនៃទ្រង់។

- **<u>គម្ពីរលោកុប្បត្តិ</u>** ១.២៦-២៧ បញ្ជាក់សេចក្ដីនេះថា ៖ «[២៦] ព្រះជាម្ចាស់មានព្រះបន្ទូលថា៖ «យើងបង្កើតមនុស្សជាតំណាងរបស់យើង មានលក្ខណៈដូចយើង ដើម្បីឲ្យគេមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ លើសត្វស្រុកនៅលើផែនដីទាំងមូល និងលើសត្វទាំងប៉ុន្មានដែលលូនវារនៅលើដី»។[២៧] ព្រះជាម្ចាស់បានបង្កើតមនុស្សជាតំណាងរបស់ព្រះអង្គព្រះអង្គបានបង្កើតគេឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ព្រះអង្គបានបង្កើតគេជាបុរសជាស្ត្រី។

តើតម្លៃអ្វីខ្លះដែលយើងអាចបរិយាយអំពីជីវិតមនុស្សលោក? ឬថាយើងត្រូវយល់ពីតម្លៃរបស់មនុស្សយើងដោយរបៀបណាខ្លះ?

១-***តម្លៃដែលមានជាប់ពីកំណើត*** មនុស្សលោកគ្រប់រូបមានតម្លៃជាប់ពីកំណើតមក ព្រោះគ្រប់មនុស្សទាំងអស់ត្រូវបានបង្កើតឡើងឲ្យមានលក្ខណៈដូចព្រះជាម្ចាស់។ ទស្សនៈវិទូលោកិយមួយរូបបានថ្លែងថា ៖«មនុស្សមានតម្លៃ ឬអត់តម្លៃ សម និង មិនសមទទួលការការពារ អាស្រ័យលើមុខងារ ឬសមត្ថភាព»។ ប៉ុន្តែ ទស្សនៈនៅព្រះគម្ពីរវិញបានថ្លែងថា ៖«បើអ្នកជាមនុស្សលោក អ្នកប្រាកដជាមានតម្លៃជាប់តាំងពីកំណើតមក ព្រោះព្រះជាម្ចាស់បានបង្កើតអ្នកមកឲ្យមានលក្ខណៈដូចព្រះអង្គ»។

២-***តម្លៃស្មើភាព*** គ្រប់មនុស្សទាំងអស់ ទាំងប្រុស ទាំងស្រី សុខភាពល្អ ឬពិការ គ្រប់ជាតិពន្ធុទាំងអស់ គឺមាន

តម្លៃស្មើភាពគ្នា ព្រោះព្រះជាម្ចាស់បានបង្កើតគេមកឲ្យមានលក្ខណៈដូចព្រះអង្គស្មើៗគ្នា។

*៣-តម្លៃលើសពីធម្មតា* គ្រប់សភាវៈជាមនុស្សលោកទាំងអស់ មានតម្លៃខ្លាំងណាស់ គឺមានតម្លៃលើសជាងអ្វីៗទាំងអស់នៅក្នុងមាបនកម្មរបស់ព្រះជាម្ចាស់។ មិនថាលោកអ្នកសម្លាប់មាន់ដើម្បីចិញ្ចឹមកូន ឬសម្លាប់កូនដើម្បីចិញ្ចឹមមាន់នោះទេ។ មានន័យថា ការយកជីវិតមនុស្សទៅប្តូរជាមួយអ្វីផ្សេងទៀតដែលមានតម្លៃថោក (ដូចជាលុយកាក់ កេរ្តិ៍ឈ្មោះ និង ភាពសុខស្រួល)។

*៤-តម្លៃដ៏នៅអស់កល្ប* ក្នុងនាមមនុស្សដែលមានលក្ខណៈដូចព្រះជាម្ចាស់ដ៏អស់កល្ប យើងកាន់កាប់សេចក្តីថ្លៃថ្នូរដ៏ពិសេស និង ជោគវាសនាដ៏អស់កល្បជាមួយព្រះជាម្ចាស់ ឬឃ្លាតឆ្ងាយពីព្រះជាម្ចាស់។ គ្រិស្តបរិស័ទស្តាយការទទួលខុសត្រូវប្រព្រឹត្តចំពោះមនុស្សដោយសេចក្តីថ្លៃថ្នូរទាំងពាក្យសម្តី កិរិយាប្រព្រឹត្ត ការទាញមនុស្សឲ្យកែប្រែចិត្តគំនិត ការមានជំនឿក្នុងព្រះគ្រិស្ត និងការមានជីវិតអស់កល្បជានិច្ច។

## តើដែលថាមនុស្សត្រូវបានបង្កើតឡើងឲ្យមានលក្ខណៈដូចព្រះជាម្ចាស់ ជាប់ទាក់ទងនឹងអ្វីខ្លះ?

*១-យើងទាំងអស់គ្នាមានសិទ្ធិមនុស្ស* គ្រប់មនុស្សលោកទាំងអស់ត្រូវបានព្រះជាម្ចាស់ដ៏ជាព្រះដែលបង្កើតប្រទានឲ្យមានសិទ្ធិមនុស្ស ហៅថា សិទ្ធិពីកំណើត។ ក្នុងចំណោមសិទ្ធិទាំងអស់ សិទ្ធិរស់រាមានជីវិត គឺសំខាន់ជាងគេបង្អស់ គ្មានសិទ្ធិនេះ គឺយើងបាត់បង់សិទ្ធិគ្រប់យ៉ាង។

*២-យើងទាំងអស់គ្នាមានចំណែកកាតព្វកិច្ចសីលធម៌ក្នុងការការពារសិទ្ធិអ្នកដទៃ* ។ យើងស្តាយកាតព្វកិច្ចការពារសិទ្ធិអ្នកដទៃ ដូចជាការការពារសិទ្ធិរបស់ជនក្រីក្រ (សុភាសិត ២៩.៧) ជនដែលរងទុក្ខវេទនា (សុភាសិត ៣១.៥) ទុគ៌តជន (សុភាសិត ៣១.៨) និង មនុស្សក្រលំបាកដែលមានសេចក្តីត្រូវការ (សុភាសិត ៣១.៩) ព្រោះជាដំបូងអ្នក ទាំងនោះត្រូវមានសិទ្ធិរបស់ខ្លួនសិន ដែលសិទ្ធិនោះត្រូវបានអ្នកផ្សេងមិនយកចិត្តទុកដាក់ ឬបដិសេធន៍ ហើយក៏គ្មានអំណាចការពារខ្លួនឯងបាន។

*៣-បើយើងស្រឡាញ់ព្រះជាម្ចាស់ យើងក៏ត្រូវស្រឡាញ់ដទៃដែរ* ។ មានបន្ទាត់សីលធម៌ពីកំណើតរវាងការស្រឡាញ់ព្រះជាម្ចាស់ និងការស្រឡាញ់អ្នកដទៃ។ ការសង្កត់សង្កិនអ្នកទន់ខ្សោយ មានន័យស្មើនឹងការប្រមាថព្រះជាម្ចាស់ (សុភាសិត ១៤.៣១)។ យើងលើកតម្កើងព្រះជាម្ចាស់ផង និងដាក់បណ្តាសារមនុស្សដែលព្រះអង្គបង្កើតមកឲ្យមានលក្ខណៈដូចព្រះអង្គផង (យ៉ាកុប ៣.៩)។

*៤-តម្លៃរបស់មនុស្សលោកបម្រុងយើងឲ្យធ្វើការល្អ ។* តម្លៃដែលមានជាប់ពីកំណើត តម្លៃស្មើភាព តម្លៃលើសពីធម្មតា តម្លៃដ៏នៅអស់កល្បនៃមនុស្សលោក ជាគោលការណ៍ជម្រុញសម្រាប់ធ្វើការល្អ។ គ្រប់ទាំងកិច្ចការនៃសេចក្តីយុត្តិធម៌ និង កិច្ចការមេត្តាករុណាត្រូវបានធ្វើចំពោះមនុស្សទន់ខ្សោយ មនុស្សគ្មានអំណាច និង ជនដែលត្រូវគេសង្កត់សង្កិន។ (សូមអាន យ៉ូប ២៩.១២-១៧, ៣០.១៣-១៥)។

ទស្សនៈគ្រិស្តបរិសទស្តីអំពីតម្លៃមនុស្សមានមូលដ្ឋានលើជម្រើសរបស់ព្រះជាម្ចាស់ក្នុងការបង្កើតមនុស្សឲ្យមានលក្ខណៈដូចព្រះអង្គ (លោកុប្បត្តិ ១.២៦-២៨)។ ដូច្នេះហើយ យើងសូមបញ្ជាក់ថា គ្រប់ជីវិតមនុស្សលោកត្រូវបានបង្កើតមកដោយមានតម្លៃជាប់ពីកំណើត តម្លៃស្មើភាព តម្លៃលើសពីធម្មតា តម្លៃដ៏នៅអស់កល្បដែលភ្ជាប់មកជាមួយនូវសិទ្ធិពីកំណើត សិទ្ធិនៃការរស់រានមានជីវិតជាសិទ្ធិទី១។ វាជារឿងងសមទំនងណាស់ដែលថាបុគ្គលម្នាក់ និង ស្ថាប័នមានសមត្ថកិច្ច (ដូចជារាជរដ្ឋាភិបាលជាដើម) ត្រូវគោរពសិទ្ធិមនុស្សដែលមានពីកំណើត ព្រោះថា សិទ្ធិនៃភាពស្មើភាពគ្នានេះ ព្រះជាម្ចាស់ជាអ្នកប្រទានឲ្យ។

## តើព្រះជាម្ចាស់មានឥរិយាបថបែបណាទាក់ទងការបង្កើតកូន និង គ្រួសារ ?

ព្រះជាម្ចាស់ផ្តល់តម្លៃដល់កុមារខ្លាំងណាស់ ហើយទ្រង់បានបង្គាប់ឲ្យយើងទទួលស្វាគមន៍ពួកគេផង។ នៅគ្រានៃការបង្កើត ព្រះអង្គបានបង្គាប់មនុស្សថា ៖ *«ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើងពាសពេញលើផែនដី»* ដោយប្រទានករណិយកិច្ចឲ្យស្វាមីភរិយាក្នុងការបង្កើតកូន ព្រមទាំងតាំងឲ្យមានវដ្តនៃគ្រួសារ គឺឲ្យមានកូន និង ត្រូវចិញ្ចឹមកូនដែលត្រូវកើតមក តាមរយៈការផ្សំផ្គុំបុរសម្នាក់ និងស្ត្រីម្នាក់ជាប្តីប្រពន្ធ របស់ព្រះជាម្ចាស់ (លោកុប្បត្តិ ១.២៨, ម៉ាថាយ ១៩.៤-៦)។ ព្រះជាម្ចាស់ប្រទានពរ (នៅក្នុងការបង្កើត និង គ្រាក្រោយទឹកជំនន់ លោកុប្បត្តិ ៩.១ និង ៧) ដល់សម្ព័ន្ធភាព និង សេចក្តីបង្គាប់នេះ។

គម្ពីរលោកុប្បត្តិ ១.២៨ ចែងថា ៖ *ព្រះជាម្ចាស់បានប្រទានពរឲ្យគេ គឺព្រះអង្គមានព្រះបន្ទូលថា៖ «ចូរបង្កើតកូនចៅឲ្យបានកើនច្រើនឡើងពាសពេញលើផែនដី ហើយត្រួតត្រាផែនដីទៅ។ ចូរមានអំណាចលើត្រីសមុទ្រ លើបក្សាបក្សីដែលហើរនៅលើមេឃ និងលើសត្វទាំងប៉ុន្មានដែលលូនវារនៅលើដី»*។

ជនជាតិអ៊ីស្រាអែលជំនាន់បូរាណចាត់ទុកកូនចៅជាព្រះអំណោយទានមកពីព្រះជាម្ចាស់ ជាព្រះពរ ជាមត៌ក និងជារង្វាន់ដ៏រីករាយ (ទំនុកតម្កើង ១២៧.៣-៥ និងជំពូក ១២៨)។ ជួនកាល ទាល់តែមានការអធិស្ឋានទូលអង្វរ ទើបគេអាចមានកូនបាន ហើយការមានកូនក៏ជាសញ្ញានៃការគាប់ព្រះហឫទ័យរបស់ព្រះជាម្ចាស់ផងដែរ ដូចជាបទពិសោធន៍របស់អ្នកស្រីហាណាដែលមានកត់ត្រានៅក្នុងគម្ពីរ១សាំយ៉ូអែល ១.១៧-២០, ២៧ និង ២.១៨-២១ជាដើម។

គម្ពីឬទំនុកតម្កើង ១២៧.៣-៥ ចែងបញ្ជាក់សេចក្តីនេះថា ៖ «[៣] <u>កូនចៅជាកេរមត៌ក</u> (ឬអំណោយ) ដែលព្រះអម្ចាស់ប្រទានឲ្យ និង<u>ជាព្រះពរមក</u>ពីព្រះអង្គ។[៤] កូនប្រុសៗដែលកើតមកក្នុងពេលដែលឪពុកនៅក្មេងនៅឡើយ ប្រៀបបាន នឹងព្រួញរបស់អ្នកចំបាំងដូច្នោះដែរ។ [៥] <u>អ្នកណាមានកូនប្រុសច្រើន ដូចព្រួញពេញក្នុងបំពង់ អ្នកនោះមានសុភមង្គល</u>ហើយ ដ្បិតពេលណាគេត្រូវតយុទ្ធជាមួយបច្ចាមិត្ត នៅមាត់ទ្វារក្រុងគេនឹងមិនត្រូវខ្មាសសោះឡើយ»។

ព្រះយេស៊ូបានបញ្ជាក់អះអាង និងឲ្យតម្លៃដល់កុមារ ព្រះអង្គទទួលស្វាគមន៍ពួកគេ ប្រទានពរដល់គេ និងអធិស្ឋានឲ្យពួកគេផង។ ព្រះអង្គបានចំណាយពេលជាមួយគេ ឱបក្រសោបពួកគេដោយព្រះហស្តទ្រង់ផ្ទាល់ ទ្រង់ក៏មានព្រះបន្ទូលជាមួយគេ ព្រមទាំងអធិស្ឋានឲ្យពួកគេផង។ ព្រះអង្គថែមទាំងយកពួកគេធ្វើជាឧទាហរណ៍អំពីការបន្ទាបខ្លួន និងការទុកចិត្ត ព្រះអង្គក៏បញ្ជាក់ថាពួកគេជាចំណុចប្រសព្វនៃជីវិតនៅក្នុងព្រះរាជ្យរបស់ព្រះជាម្ចាស់។ ព្រះអង្គក៏បានព្រមានមិនឲ្យធ្វើឲ្យទុក្ខទោស ឬរារាំងក្មេងតូចណាម្នាក់ឡើយ។

គម្ពីរម៉ាកុស ១០.១៣-១៦ បញ្ជាក់ថា ៖«[១៣] មានមនុស្សម្នានាំក្មេងតូចៗមកឲ្យព្រះយេស៊ូដាក់ព្រះហស្តលើពួកវា ប៉ុន្តែ ពួកសិស្សស្តីបន្ទោសអ្នកទាំងនោះ។ [១៤] កាលព្រះយេស៊ូឃើញដូច្នោះ ព្រះអង្គទាស់ព្រះហឫទ័យណាស់ ហើយមានព្រះបន្ទូលថា៖ «ទុកឲ្យក្មេងៗ មករកខ្ញុំចុះ កុំឃាត់ពួកវាឡើយ ដ្បិតមានតែអ្នកមានចិត្តដូចក្មេងៗទាំងនេះប៉ុណ្ណោះ ដែលចូលក្នុងព្រះរាជ្យ*ព្រះជាម្ចាស់បាន។ [១៥] ខ្ញុំសុំប្រាប់ឲ្យអ្នករាល់គ្នាដឹងច្បាស់ថា អ្នកណាមិនព្រមទទួលព្រះរាជ្យព្រះជាម្ចាស់ ដូចក្មេងតូចមួយទទួលទេ អ្នកនោះមិនអាចចូលក្នុងព្រះរាជ្យព្រះអង្គបានឡើយ»។ [១៦] បន្ទាប់មក ព្រះអង្គឱបក្មេងទាំងនោះ រួចប្រទានពរឲ្យពួកវា ដោយដាក់ព្រះហស្តពីលើ»។

គម្ពីរម៉ាថាយ ១៨.៥-៦ ចែងថា ៖«[៥] អ្នកណាទទួលក្មេងតូចណាម្នាក់ដូចក្មេងនេះ ក្នុងនាមខ្ញុំ ក៏ដូចជាបានទទួលខ្ញុំដែរ [៦]អ្នកណានាំអ្នកតូចតាចម្នាក់ក្នុងបណ្តាអ្នកដែលជឿលើខ្ញុំនេះ ឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នកនោះ ប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងកគាត់ ទម្លាក់ទៅក្នុងបាតសមុទ្រឲ្យលង់ទឹក ប្រសើរជាងទុកគាត់ឲ្យនៅរស់!»។

នៅក្នុងគម្ពីរលោកុប្បត្តិ ១.២៨ ព្រះជាម្ចាស់បានប្រទានបទបញ្ជាដល់មនុស្សលោក គឺឲ្យគេបង្កើតកូនឲ្យបានច្រើន ។ ព្រះជាម្ចាស់ឲ្យតម្លៃដល់ការបង្កើតកូន និងការចិញ្ចឹមគ្រួសារដែលជាសញ្ញានៃគាប់ព្រះហឫទ័យ និងការចម្រុងចម្រើនដល់គេរបស់ព្រះអង្គ។ ពួកគេជាព្រះពរ និងជារង្វាន់ដែលត្រូវទទួលស្វាគមន៍ និងចិញ្ចឹមបីបាច់។ គួរឲ្យស្តាយណាស់ បច្ចុប្បន្ននេះ មានមនុស្សមួយចំនួនមើលឃើញកូនៗជាមេរំខាន ជាបន្ទុក និងគ្មានប្រយោជន៍សម្រាប់គេឡើយ គេមិនឲ្យតម្លៃថាជាព្រះពរពីព្រះជាម្ចាស់ដែលការពិតកូនជាព្រះពរពីព្រះជាម្ចាស់ពិតមែន។

## តើជីវិតចាប់ផ្តើមឡើងពីពេលណា? តើទារកដែលមិនកើតមកជាមនុស្សលោកឬទេ? តើព្រះគម្ពីរចែងដូចម្តេច? ចុះតើខាងខាងវិទ្យាសាស្ត្រវិញ និយាយបែបណា?

ព្រះជាម្ចាស់បង្ហាញថា «គភ៌» ជាការចាប់ផ្តើមនៃជីវិតរបស់មនុស្សលោក ហើយព្រះអង្គមិនបែងចែករវាងកុមារដែលមានដំណាក់កាលរីកធំធាត់ជាមនុស្សពេញវ័យខុសៗគ្នានោះទេ ទាំងទារកក្នុងផ្ទៃក្តី ទារកដែលទើបនឹងកើតក្តី ទាំងកូនក្មេងដែលទើបចេះដើរក្តី ឬយុវជនក្តី។ ព្រះអង្គទតមើលពួកគេថាជាមនុស្សលោកទាំងអស់ ហើយព្រះអង្គហៅគេថា ជាបុត្ររបស់ព្រះអង្គផង។ ព្រះបាទដាវីឌ បានឃើញការវិវឌ្ឍន៍នៃកំណើតរបស់ខ្លួនឯងនៅក្នុងផ្ទៃម្តាយថាជាកិច្ចការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់។

ទី១-ព្រះជាម្ចាស់ប្រើពាក្យដូចគ្នាទៅបរិយាយទារកក្នុងផ្ទៃ និង ទារកដែលបានកើតមក ហើយព្រះអង្គបានធ្វើដូច្នេះទាំងក្នុងសម្ព័ន្ធមេត្រីចាស់ដែលសរសេរជាភាសាហេប្រឺ និងក្នុងសម្ព័ន្ធមេត្រីថ្មីដែលសរសេរជាភាសាក្រិក។

**ក-សម្ព័ន្ធមេត្រីចាស់**

ពាក្យថា «កូន» ជាភាសាហេប្រឺគេហៅថា ៖ «ហាបានិម» បានប្រើប្រាស់សម្រាប់បរិយាយទាំងទារកដែលនៅក្នុងផ្ទៃ និង ទាំងទារកដែលបានកើតមក។

គម្ពីរលោកុប្បត្តិ ២៥.២២ ចែងអំពីទារកភ្លោះដែលនៅក្នុងផ្ទៃនាងរេបេកាថា ៖«ដោយទារកកំរើកប៉ះគ្នានៅក្នុងផ្ទៃ...»។

គម្ពីរទំនុកតម្កើង ១២៨.៣ ប្រើពាក្យដូចគ្នាដែលសម្គាល់ថាជា «កូន » ជាលក្ខណៈទូទៅដូច្នេះថា ៖ « នៅក្នុងផ្ទះភរិយារបស់អ្នកប្រៀបដូចជាដើមទំពាំងបាយជូរដែលមានផ្លែជាច្រើន ហើយនៅជុំវិញតុ កូនប្រុសៗរបស់អ្នកក៏ប្រៀបបាននឹងដើមអូលីវតូចៗដែរ»។

**ខ-សម្ព័ន្ធមេត្រីថ្មី**

ពាក្យក្រិកដែលបកប្រែថា «កូន» គឺ «ប្រេផុស» ត្រូវបានប្រើសម្តៅទាំងទារកក្នុងផ្ទៃ និងទារកដែលទើបនឹងកើត។

- លូកា ១.៤១ «ពេលនាងអេលីសាបិតឮនាងម៉ារីជំរាបសួរ ទារកនៅក្នុងផ្ទៃនាងបម្រាសឡើង ហើយគាត់ក៏បានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ»។
- លូកា ២.១៦ «ពួកគេប្រញាប់ប្រញាល់នាំគ្នាធ្វើដំណើរទៅ ឃើញនាងម៉ារីលោកយ៉ូសែប ព្រមទាំងព្រះឱរសផ្ទំក្នុងស្នូកសត្វ»។

ទី២ ព្រះជាម្ចាស់បង្ហាញថា ការមានគភ៌ជាការចាប់ផ្តើមជីវិតរបស់មនុស្ស។ ព្រះគម្ពីរថ្លែងយ៉ាងច្បាស់លាស់ទាក់ទងនឹងគោលគំនិតនៃជីវិតមនុស្សលោក មានផ្ទៃពោះជាកូនប្រុសមួយ (គឺមិនមែនស៊ុតបង្ករកំណើត (ស៊ីកូត) ឬជាកញ្ចុំនៃកោសិកា) ជាធម្មតាប្រើបរិយាយអំពីទម្រង់នៃរូបមន្តកំណើត ការមានផ្ទៃពោះ និងការសម្រាលកូន។

- លោកុប្បត្តិ ៤.១ «លោកអដាំរួមរស់ជាមួយនាងអេវ៉ាជាភរិយា នាងមានផ្ទៃពោះសំរាលបានកូនមួយឈ្មោះកាអ៊ីន នាងពោលថា៖ «ខ្ញុំបានបង្កើតមនុស្សម្នាក់ ព្រោះ**ព្រះអម្ចាស់**ប្រទានឲ្យ»។ តើជីវិតរបស់ កាអ៊ីនចាប់ផ្តើមតាំងពីពេលណាមក? គឺផ្តើមដោយគភ៌។

- លូកា ១.៣១ ទេវតាប្រាប់នាងម៉ារាថា ៖«នាងនឹងមានគភ៌ សំរាលបានបុត្រមួយដែលនាងត្រូវថ្វាយព្រះនាមថា “យេស៊ូ” ។

- លូកា ១.៣៦ ទេវតាក៏ប្រាប់នាងម៉ារាថា ៖«ម្យ៉ាងទៀត នាងអេលីសាបិត ជាញាតិរបស់នាង មានផ្ទៃពោះប្រាំមួយខែហើយ ថ្វីដ្បិតតែគាត់មានវ័យចាស់ ថែមទាំងជាស្រ្តីអារទៀតផងក៏ដោយ»។

តើគភ៌ដែលនៅក្នុងផ្ទៃនាងម៉ារានោះជាអ្វី? គឺជាបុត្រាមួយអង្គ។ ចុះតើគភ៌នៅក្នុងផ្ទៃអ្នកស្រីអេលីសាប៉ែតវិញជាអ្វីដែរ? គឺជាកូនប្រុសម្នាក់។ តើព្រះឱរស្មយេស៊ូ និងទារកយ៉ូហានបានក្លាយជាបុត្រ (សភាវៈជាមនុស្សលោក)ផ្តើមមានជីវិតតាំងពីពេលណាមក? គឺផ្តើមដោយសារគភ៌។

ទី៣-នៅពេលនាងម៉ារាទៅសួរសុខទុក្ខអ្នកស្រីអេលីសាប៉ែត ទារកយ៉ូហានដែលនៅក្នុងផ្ទៃនាង បម្រាសដោយអំណរតាមរបៀបជាមនុស្សលោក នៅចំពោះព្រះវត្តមាននៃព្រះឱរស្មយេស៊ូដែលកំពុងនៅក្នុងផ្ទៃនាងម៉ារាដែរនោះ។ ថ្វីដ្បិតនៅតូចខ្ចីក៏ដោយក៏ព្រះឱរស្មយេស៊ូមានព្រះវត្តមានយ៉ាងពេញលេញក្នុងផ្ទៃនាងម៉ារា។ ក្នុងសាច់រឿង បានបញ្ជាក់អះអាងយ៉ាងពេញអំណាចអំពីមនុស្សលោកដែលជាទារកស្ថិតនៅក្នុងផ្ទៃនៅឡើយ។

- *ការទទួលស្គាល់* និង *ការបម្រាសដោយអំណរជាការឆ្លើយតបក្នុងនាមជាមនុស្សលោក* គឺជាមនុស្សម្នាក់។ ទារកយ៉ូហានដែលនៅក្នុងផ្ទៃបានប្រកាសអំពីការយាងមកដល់របស់ព្រះអម្ចាស់ថា «អ្នកម្តាយអើយ ព្រះយេស៊ូបានយាងមកដល់ហើយ!» ដូចជាអ្វីដែលលោកបានប្រកាសប្រាប់មនុស្សជាច្រើននៅសាមសិបឆ្នាំក្រោយមក (យ៉ូហាន ១.២៩)។ ពេលអ្នកស្រីអេលីសាបិតឮនាងម៉ារីជំរាបសួរ ទារកនៅក្នុងផ្ទៃនាងបម្រាសឡើង ហើយគាត់ក៏បានពោរពេញដោយព្រះវិញ្ញាណដ៏វិសុទ្ធ រួចបន្លឺសំឡេងឡើងថា៖ «……កាលខ្ញុំបានឮពាក្យជំរាបសួររបស់នាង ស្រាប់តែកូននៅក្នុងផ្ទៃខ្ញុំបម្រាសឡើងដោយអំណរសប្បាយ» (លូកា ១.៤០-៤៤)។

- ព្រះយេស៊ូ បានយាងមកដល់ហើយ ! ទ្រង់ជាព្រះមួយរយភាគរយ និងជាមនុស្សមួយរយភាគរយ ព្រះអង្គមានព្រះវត្តមានយ៉ាងពេញលេញ ទោះបីព្រះអង្គស្ថិតនៅជាដុំឈាមជីវិតតូចមួយក្នុងចន្លោះនៃពេលវេលាមួយ ហើយប្រាកដជាមិនទាន់មានទម្រង់ជារូបភាពមនុស្សលោកច្បាស់លាស់នៅក្នុងផ្ទៃនៅឡើយផង។ ស៊ុតបង្ករកំណើតបានអភិវឌ្ឍន៍ឡើង (ក្នុងអំឡុងពេលពីរបីម៉ោង ឬមួយថ្ងៃ ឬប្រហែលមួយសប្តាហ៍) ប៉ុន្តែទារកយ៉ូហានបានប្រកាសអំពីការមកដល់របស់ព្រះអង្គតាំងពីលោកនៅជាទារកក្នុងផ្ទៃមកម្លេះ!

តើយើងដឹងដោយរបៀបណា ដែលថាព្រះយេស៊ូនៅតូចបានយាងមកដល់ហើយនោះ? សូមអានគម្ពីរលូកា ១.២៦-៤៤, ៥៦-៥៧។

នៅពេលទេវតាមកប្រាប់ដំណឹងអំពីការមានផ្ទៃដោយឫទ្ធានុភាពនៃព្រះវិញ្ញាណដ៏វិសុទ្ធដល់នាងម៉ារា ពេលហ្នឹងនាងមិនទាន់មានគភ៌ទេ (ខ២៦)។ នាងម៉ារាប្រញាប់ប្រញាល់ធ្វើដំណើរទៅសួរសុខទុក្ខអ្នកស្រីអេលីសាប៉ែត (ខ៣៩)។ ផ្អែកលើ ស្ថានភាពផ្លូវដែលនាងធ្វើដំណើរ យ៉ាងហោចណាស់នាងម៉ារាធ្វើដំណើរចន្លោះ

១១៥-១៥០គីឡូម៉ែត្រ ពីភូមិណាសារ៉ែតនៅភាគខាងជើងឆ្ពោះទៅភូមិរបស់អ្នកស្រីអេលីសាប៊ែតដែលស្ថិតនៅតំបន់ភ្នំស្រុកយូដា (១.៣៩) ភាគខាងត្បូងឆៀងខាងលិចក្រុងយេរូសាឡឹម ទំនងជាមិនឆ្ងាយប៉ុន្មានទេ ព្រោះលោកសាការីបានមកបម្រើកិច្ចការនៅក្នុងព្រះវិហារក្រុងយេរូសាឡឹម (១.៥-៩)។

ពេលនាងម៉ារាបាននឹងកំពុងធ្វើដំណើរទៅភូមិនោះ ពោះនាងក៏ធំឡើងជាលំដាប់។ ពោលគឺចាប់តាំងក្រោយដែលទេវតាបានប្រកាសប្រាប់មក នៅមុនពេលនាងម៉ារាទៅសួរសុខទុក្ខបងស្រីរបស់ខ្លួន ព្រះយេស៊ូផ្តើមជាគភ៌ ក្នុងវេលាសមគួរមួយរួចទៅហើយ។ ព្រះយេស៊ូមានចលនាជីវិតនៅក្នុងផ្ទៃនាងម៉ារា តាំងពីរបីម៉ោង ឬពីរបីថ្ងៃមុនពេលនាងម៉ារាទៅ សួរសុខទុក្ខអ្នកស្រីអេលីសាប៊ែតមកម្ល៉េះ។




គួរកត់សម្គាល់ថា នៅពេលទារកយ៉ូហានបម្រាសដោយអំណរចំពោះព្រះវត្តមាននៃព្រះយេស៊ូ ជាព្រះជាម្ចាស់ដែលចាប់កំណើត (ឬចាប់បដិសណ្ធិ)ជាមនុស្សលោកនោះ ព្រះយេស៊ូស្ថិតនៅជាដុំជីវិតដ៏តូច ប៉ុន្តែជាព្រះជាម្ចាស់មួយរយភាគរយ និង ជាមនុស្សមួយរយភាគរយ។

ព្រឹត្តិការណ៍នេះបានកើតឡើង ស្របពេលដែលអ្នកស្រីអេលីសាប៊ែតកំពុងមានផ្ទៃពោះប្រាំមួយខែហើយ (១.៣៦) ឯទារកយ៉ូហានមានទំហំប៉ុន-កដៃមនុស្សប្រុសពីក្បាលទៅត្រគៀក។ នាងម៉ារាបានទៅដល់ហើយស្នាក់នៅទីនោះបីខែទៀត រួចមកនាងក៏ត្រឡប់មកផ្ទះវិញនៅមុនពេលទារកយ៉ូហានកើត (១.៥៦-៥៧)។ ការបញ្ជាក់ចុងក្រោយនេះ គឺជាព្រឹត្តិការណ៍គួរឲ្យកត់សម្គាល់ក្នុងគម្ពីរលូកា ១.២៦-៤៤ កើតឡើងចន្លោះពេលពីរបីថ្ងៃឬប្រហែលមួយសប្តាហ៍ហើយទារកដែលនៅក្នុងផ្ទៃនោះគឺជាមនុស្សពេញលក្ខណៈ។ តើវិទ្យាសាស្ត្របង្រៀនដូចអ្វីដែលព្រះគម្ពីរបង្រៀនឬទេដែលថាជីវិតមនុស្សចាប់ផ្តើមពីការមានគភ៌? គឺពិតមែន។ វិទ្យាសាស្ត្រផ្នែកទារកសាស្ត្របង្រៀនយើងថា ការមានគភ៌ (ការចាប់កំណើត) របស់មនុស្សគឺ ៖

១)-សភាវៈ*មានជីវិត* ជាមនុស្សលោក ។

២)-សភាវៈ *លក្ខណៈផ្សេងគ្នា* ជាមនុស្សលោក ។

៣)-សភាវៈ *ពេញលេញ* ជាមនុស្សលោក ដែលមានវត្តមាន និងអភិវឌ្ឍន៍ ព្រមទាំងពេញរូបពេញរាងពីខាងក្នុងផង។

- ផ្តើមពីចំណុចនេះទៅពុំមានអ្វីត្រូវបន្ថែមទេ លើកលែងតែការចិញ្ចឹមប៉ុណ្ណោះ!
- សភាវៈជាមនុស្សលោក មានលក្ខណៈផ្សេងគ្នាពីឪពុក និងម្តាយរបស់ខ្លួន។ វាមានលក្ខណៈរួម។ មានឌីអ៊ែនអេ (DNA) មានប្រភេទឈាម មានភេទ មានក្រយ៉ៅដៃ និងក្រយ៉ៅជើង មានភ្នែក និង ពណ៌សក់ ទំហំរាងកាយ និងមុខមាត់។ល។ ផ្សេងគ្នា។

អ្នកជំនាញផ្នែកទារកសាស្ត្រនាមលោក ខេត អ៊ែ មូរ៉េ (Keith L. Moore) មានប្រសាសន៍ថា ៖ «កោសិការបង្ករកំណើត ជាការចាប់ផ្តើមនៃជីវិតមនុស្សលោក។ ការអភិវឌ្ឍន៍ជីវិតមនុស្សចាប់ផ្តើមដោយការបង្ករកំណើតអំឡុងពេលមេជីវិតឈ្មោល ឬទឹកកាមបុរស....បានរួមបញ្ចូលគ្នាជាមួយនឹងមេជីវិតញី ឬទឹកកាមស្ត្រី...បង្កើតជាកោសិការមួយហៅថា កោសិការបង្ករកំណើត។ បច្ចេកទេសដ៏ខ្ពស់នៃសក្តានុពលកោសិការ

ហៅថានិមិត្តសញ្ញានៃការចាប់នៃជីវិតឯកត្តបុគ្គលដ៏ពិសេស (Keith L .Moore, TVN Persaud, *The Developing Human: Clinically Oriented Embryology)* ។.

អ្នកជំនាញផ្នែកកាយវិទ្យា នាមលោក ចន-ខ្លាក (*John Clark)* មានប្រសាសន៍ថា ៖ «ជីវិតមនុស្សផ្តើមឡើង ដោយការរួមបញ្ចូលរវាងកោសិកាពីរប្រភេទ កោសិកាញី ឬស៊ុតជីវិតញី រួមគ្នាជាមួយមេជីវិតឈ្មោលដែលតូចជាង។ ជាលិកាដ៏តូចល្អិតនេះ មានផ្ទុកគ្រប់ព័ត៌មានចាំបាច់នានាក្នុងការចម្រើនធំធាត់ក្នុងរចនាសម្ព័ន្ធដ៏ស្មុគ្រស្មាញនៃរាងកាយមនុស្សលោក។ កោសិការបស់ម្តាយផ្តល់ការចិញ្ចឹម និង ការការពារ (-*Clark, J. The Nervous System: Circuits of Communication in the Human Body, Torstar Books)* ។




ជីវិតចាប់ផ្តើមពេលមេជីវិតឈ្មោល និងមេជីវិតញីជួបគ្នាហៅថា គភ៌។ ជីវិតនៅក្នុងផ្ទៃអស្ចារ្យណាស់ និងជាហេតុផលដែលត្រូវលើកតម្កើង និងថ្វាយបង្គំព្រះជាម្ចាស់។

ព្រះបាទដាវីឌ បានមើលឃើញខ្លួនឯងជាមនុស្សពេញលេញ កាលទ្រង់ស្ថិតនៅក្នុងផ្ទៃម្តាយ ហើយបានសរលើកតម្កើងព្រះជាម្ចាស់។ ការប្រើប្រាស់សព្វនាមបុគ្គល «**ខ្ញុំ**» បង្ហាញថា ព្រះបាទដាវីឌផ្ទាល់ គឺបុគ្គលដែលនៅក្នុងផ្ទៃ និងបុគ្គលដែលកត់ត្រា គឺជាមនុស្សតែមួយ។ ភាពជាមនុស្សលោករបស់យើងនៅក្នុងផ្ទៃ មិនគ្រាន់តែជាការពិតប៉ុណ្ណោះទេ តែជារឿងអស្ចារ្យដ៏រីករាយ និង ដ៏មហស្ចារ្យផង។

ព្រះបាទដាវីឌ ឆ្លុះបញ្ចាំងពីសភាវៈដែលបានកកើតនៅក្នុងផ្ទៃម្តាយ និងបានលើកតម្កើងព្រះជាម្ចាស់ថា ៖ «
[១៣] ព្រះអង្គបានបង្កើតទូលបង្គំមក ព្រះអង្គបានបង្កប់ទូលបង្គំនៅក្នុងផ្ទៃម្តាយ។ [១៤] ទូលបង្គំសូមលើកតម្កើង



ព្រះអង្គ ដ្បិតទូលបង្គំជាស្នាព្រះហស្តដ៏ល្អអស្ចារ្យទូលបង្គំដឹងច្បាស់ថាអ្វីៗដែលព្រះអង្គធ្វើសុទ្ធតែល្អអស្ចារ្យទាំងអស់» (ទំនុកតម្កើង (១៣៩.១៣-១៤)។
សូមទស្សនាវីដេអូរនៃការវឌ្ឍន៍របស់គភ៌យ៉ាងអស្ចារ្យ នៃជីវិតរបស់អ្នកមុនចាប់កំណើតជាទារក (៦នាទី)។ បង្ហាញទារកក្នុងផ្ទៃ។ ការបង្ហាញមួយដ៏អស្ចារ្យ។ សូមចូលទៅគេហទំព័រតំណរភ្ជាប់៖ www.baovemamsong.org /media , ឬស្កែនកូនQR នេះក៏បាន។

## សំណួរទី២ -តើព្រះជាម្ចាស់មានព្រះបន្ទូលអ្វីខ្លះអំពីការបង្ហូរឈាមមនុស្សស្លូតត្រង់ រួមទាំងការរំលូតកូនផង?

អ្វីដែលព្រះស្រឡាញ់ជាងគេ ព្រះអង្គក៏ការពារជាងគេដែរ។ ក្នុងសំណួរទី២នេះ យើងឃើញរបៀបដែលច្បាប់របស់ព្រះជាម្ចាស់ការពារមនុស្សពីហានិភ័យ និងឃើញពីប្រតិកម្មរបស់ព្រះជាម្ចាស់ចំពោះការសម្លាប់ជីវិតជនស្លូតត្រង់ ហើយនៅចុងបញ្ចប់ យើងនឹងពិនិត្យមើលពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចំពោះការសម្លាប់កូនក្មេង និង ការរំលូតកូន។

តើព្រះជាម្ចាស់ការពារអ្វីដែលព្រះអង្គស្រឡាញ់ជាងគេក្នុងមាបនកម្មរបស់ព្រះអង្គ ដោយរបៀបណា? វិធីសាស្ត្របឋមដែលព្រះជាម្ចាស់ការពារជីវិតមនុស្សលោក គឺតាមរយៈច្បាប់សីលធម៌របស់ព្រះអង្គ និងតាមរយៈការបង្កើតមនុស្សទាំងអស់ ឲ្យមានមនសិការទាក់ទងនឹងច្បាប់ទាំងនោះ ។ ច្បាប់សីលធម៌របស់ព្រះជាម្ចាស់ (ក៏ជាច្បាប់ចរិយាសាស្ត្រនៃព្រះគម្ពីរផងនោះ) អាចសរុបដោយសង្ខេបត្រឹមប៉ុន្មានម៉ាត់នេះថា ៖«ត្រូវស្រឡាញ់អ្នកអ្នកដទៃឲ្យបានដូចខ្លួនឯង» (លេវីវិន័យ ១៩.១៨)។

ច្បាប់សីលធម៌ជាបទបញ្ជារបស់ព្រះជាម្ចាស់ទាំងទម្រង់វិជ្ជមាន និង ទម្រង់អវិជ្ជមាន ៖

- ទម្រង់អវិជ្ជមានថ្លែងថា ៖ «កុំសម្លាប់មនុស្ស» (និក្ខមនំ ២០.១៣)។
- ទម្រង់វិជ្ជមានថ្លែងថា ៖ «ត្រូវស្រឡាញ់អ្នកដទៃឲ្យដូចខ្លួនឯង។ យើងជាព្រះអម្ចាស់»(លេវីវិន័យ១៩.១៨)។

ច្បាប់ទម្រង់អវិជ្ជមានផ្ដើមដោយពាក្យហាមឃាត់ការសម្លាប់មនុស្ស -*ការសម្លាប់សភាវៈជាមនុស្សដែលឥតទោស ឬជនស្លូតត្រង់ដោយចេតនា*។ ឯច្បាប់វិជ្ជមានវិញ គឺផ្ដើមដោយពាក្យបង្គាប់ឲ្យមានសកម្មភាពការពារជីវិតមនុស្សលោក។ ឧទាហរណ៍ គម្ពីរចោទិយកថា ២២.៨ ចែងថា ៖«ប្រសិនបើអ្នកសង់ផ្ទះថ្មី ត្រូវធ្វើបង្កាន់ដៃព័ទ្ធជុំវិញដំបូលផ្ទះ ក្រែងលោមាននរណាម្នាក់ធ្លាក់ពីលើដំបូលបណ្ដាលឲ្យអ្នកមានទោស ព្រោះតែផ្ទះនោះ»។

ច្បាប់នេះជាទម្រង់វិជ្ជមានដែលភ្ជាប់មកជាមួយការការពារសុវត្ថិភាពរបស់អ្នកដទៃ ឯច្បាប់ជាទម្រង់អវិជ្ជមានមានចែងក្នុងគម្ពីរនិក្ខមនំ ២០.១៣ «កុំសម្លាប់មនុស្ស»។ មនុស្សលោកស្គាល់ថា នេះជារឿងត្រឹមត្រូវ និងពិតប្រាកដ ប៉ុន្តែគេអាចនឹងទាត់សេចក្ដីពិតចោលក៏ថាបាន។

ស្មោះត្រង់ចំពោះព្រះជាម្ចាស់ និង ស្ដាប់បង្គាប់ច្បាប់សីលធម៌របស់ព្រះអង្គ យើងត្រូវធ្វើកិច្ចការពីរយ៉ាង ៖

ទី១-មិនត្រូវសម្លាប់ជីវិតមនុស្សដោយចេតនា (នោះជាមនុស្សឃាត)។
ទី២-មិនបិទភ្នែកធ្វើមិនដឹងមិនឮ (ឬទទួលដោយគ្មានការជំទាស់តវ៉ា) ចំពោះការសម្លាប់មនុស្សដែលគ្មានកំហុស ឬជនស្លូតត្រង់ពីជនណាម្នាក់។

តាមពិតព្រះជាម្ចាស់បានបង្គាប់យើងឲ្យស្រឡាញ់ និងប្រព្រឹត្តចំពោះអ្នកដទៃនូវអំពើណាដែលយើងចង់ឲ្យគេ

ប្រព្រឹត្តចំពោះយើងវិញ។ បើយើងស្ថិតជាគោលដៅនៃការសម្លាប់ នោះយើងប្រាកដត្រូវការអ្នកណាម្នាក់ឲ្យនិយាយជំនួសយើង ការពារយើង ហើយសង្គ្រោះយើងពីហានិភ័យនោះជាមិនខានឡើយ។

## *តើជីវិតដែលឥតទោស ចង់មានន័យសម្តៅលើអ្វី?*

គម្ពីររ៉ូម ៣.១០ ប្រាប់យើងថា គ្មានមនុស្សលោកណាម្នាក់ឥតកំហុសសោះឡើយ។ «គ្មានអ្នកណាសុចរិតឡើយ សូម្បីតែម្នាក់ក៏គ្មានផង»។ បរិបទនេះមានន័យថា គ្មាននរណាម្នាក់ឥតទោសនៅ*ចំពោះព្រះជាម្ចាស់* សោះឡើយ មនុស្សលោកគ្រប់រូបសុទ្ធតែមានបាប ហើយត្រូវការព្រះសង្គ្រោះ។ ប៉ុន្តែ មានកន្លែងផ្សេងទៀតក្នុងបទគម្ពីរដែលនិយាយអំពីមនុស្សឥតទោស ឬមនុស្សស្លូតត្រង់ (សូមមើល សុភាសិត ១.១១, ៦.១៦-១៧)។

## *កាលណាព្រះជាម្ចាស់មានព្រះបន្ទូលសម្តៅលើជីវិតឥតទោស ឬឈាមជនស្លូតត្រង់ គឺព្រះអង្គសម្តៅលើ៖*

មនុស្សដែលឥតទោសនៅចំពោះមុខច្បាប់។ យោងតាមច្បាប់ មនុស្សគ្រប់ត្រូវបានចាត់ទុកថា ជាមនុស្សឥតទោស រហូតទាល់តែមានភ័ស្តុតាងបញ្ជាក់ពីពិរុទ្ធភាពស្របតាមនិតិវិធីនៃច្បាប់។ មនុស្សដែលត្រូវគេមួលបង្កាច់ក៏ចាត់ទុកថា ជាមនុស្សឥតទោសដែរ។ គម្ពីរនិក្ខមនំ ២៣.៦-៧ ៖ «[៦] នៅពេលកាត់ក្តី មិនត្រូវរំលោភលើសិទ្ធិរបស់ជនក្រីក្រឡើយ។ [៧] កុំយកចិត្តទុកដាក់ស្តាប់ពាក្យចោទប្រកាន់មិនពិត ហើយក៏មិនត្រូវកាត់ទោសប្រហារជីវិតជនស្លូតត្រង់ និងជនសុចរិតដែរ ដ្បិតយើងមិនចាត់ទុកមនុស្សអាក្រក់ ថាជាមនុស្សសុចរិតឡើយ»។ *មនុស្សដែលមិនអាចលូតលាស់សមត្ថភាពបែងចែកល្អនិងអាក្រក់។* ការនេះរួមមានទាំងទារកក្នុងផ្ទៃ កូនង៉ែត កុមារ និងក្មេងដែលមានសតិបញ្ញាមិនសូវល្អដែលពិបាកបែងចែកត្រូវ និងខុស។ គម្ពីរអេសាយ ៧.១៦ « ប៉ុន្តែ មុនពេលបុត្រនោះចេះបដិសេធអ្វីៗដែលអាក្រក់ហើយជ្រើសយកអ្វីៗដែលល្អ ស្រុករបស់ស្តេចទាំងពីរដែលបានមក បំភ័យព្រះករុណា នឹងត្រូវគេបោះបង់ចោលឲ្យនៅស្ងាត់ជ្រងំ» (សូមអានផងដែរនៅក្នុងគម្ពីរ ចោទិយកថា ១.៣៩, យេរេមា ១៩.៤)។

## *តើព្រះជាម្ចាស់ឆ្លើយតបទៅការសម្លាប់មនុស្សឥតទោសដោយចេតនា(ការបង្ហូរឈាមជនស្លូតត្រង់) ដោយរបៀបណា?*

ព្រះជាម្ចាស់ទ្រង់ព្រះពិរោធ និងវិនិច្ឆ័យទាស់នឹងអស់អ្នកដែលសម្លាប់មនុស្សឥតទោស ឬជនស្លូតត្រង់ ហើយព្រះអង្គញែកអង្គទ្រង់ចេញពីមនុស្សប្រភេទនោះ (ទោសនៃការបង្ហូរឈាម), ព្រះអង្គមិនស្តាប់ពាក្យអធិស្ឋានរបស់គេលើកលែងតែគេកែប្រែចិត្តគំនិត។

ក្នុងរឿងកាអ៊ីន និងអេបិល (លោកុប្បត្តិ ៤.៨-១៣) លោកកាអ៊ីន មានចេតនាសម្លាប់ប្អូនប្រុសដែលឥតទោស ឬស្លូតត្រង់របស់ខ្លួន។ លោកដឹងថា ការសម្លាប់អេបិលជារឿងមិនត្រឹមត្រូវទេ ព្រោះច្បាប់ធម្មជាតិដែលព្រះជាម្ចាស់បានកំណត់បានចារឹកក្នុងបេះដូងរបស់គាត់រួចហើយ (គឺមនសិការរបស់គាត់ហ្នឹងឯង) ទោះបីជាច្បាប់បែបវិជ្ជមាន និងច្បាប់បែបអវិជ្ជមាន មិនទាន់មានជាលាយលក្ខអក្សរនៅឡើយដែលច្បាប់នោះនឹងមាននៅជំនាន់លោកម៉ូសេប្រហែល២៥០០ឆ្នាំក្រោយមកទៀត។

លោកកាអ៊ីនដឹងអំពីច្បាប់បែបអវិជ្ជមាន «កុំសម្លាប់មនុស្ស» ហើយក៏ព្យាយាមលាក់បាំងសកម្មភាពរបស់ខ្លួនដោយការកុហក (៤.៩)។ លោកកាអ៊ីនក៏ដឹងអំពីច្បាប់បែបវិជ្ជមាន «ស្រឡាញ់អ្នកជិតខាង» លោកក៏ព្យាយាមមិនទទួលខុសត្រូវចំពោះច្បាប់បែបវិជ្ជមានដោយនិយាយថា ៖ «ទូលបង្គំមិនដឹងទេ! តើទូលបង្គំជាអ្នកឃ្វាលប្អូនរបស់ទូលបង្គំឬ?»។

-ពិតមែនហើយ គឺគាត់ត្រូវតែធ្វើអ្វីម៉្យាង! ដូចអ្វីដែលព្រះជាម្ចាស់រំពឹងទុក! ជីវិតរបស់លោកអេបិលពិតជាថ្លៃណាស់ លោកស្រែករកយុត្តិធម៌ពីព្រះជាម្ចាស់។

-ព្រះជាម្ចាស់ឆ្លើយតបចំពោះលោកកាអ៊ីនចំពោះឃាតកម្មលើលោកអេបិល។ ព្រះជាម្ចាស់ព្រះសណ្ដាប់ឮ (១០) ព្រះអង្គវិនិច្ឆ័យលោកកាអ៊ីន (១១-១២-១៣) ហើយព្រះអង្គបានញែកអង្គទ្រង់នៅឆ្ងាយពីលោកកាអ៊ីន (១២-១៤)។ ប្រតិកម្មរបស់ព្រះជាម្ចាស់ចំពោះឃាតកម្ម *(ទ្រង់ព្រះសណ្ដាប់ឮ ទ្រង់វិនិច្ឆ័យ និងញែកចេញ)* ក្នុងព្រះគម្ពីរគឺមិនប្រែប្រួល ៖

១-ព្រះអង្គស្ដាប់ឮសម្រែករបស់អ្នកដែលឈឺចាប់ដោយហឹង្សា- ដូចព្រះអង្គព្រះសណ្ដាប់សម្រែករបស់លោកអេបិលដែរ! ព្រះជាម្ចាស់ជានាអះអាង ចំពោះអស់អ្នកដែលត្រូវគេឆក់ជីវិត (ធ្វើឃាត)ថា ជីវិតរបស់គេមានតម្លៃណាស់ចំពោះព្រះអង្គ ហើយព្រះអង្គនឹងសងសឹកឃាតករដែលសម្លាប់គេនោះក្នុងពេលវិនិច្ឆ័យទោស។

- ទំនុកតម្កើង ៩.១២ «ដ្បិតព្រះអង្គដាក់ទោសអ្នកដែលសម្លាប់គេ ព្រះអង្គចងចាំជានិច្ច ព្រះអង្គមិនភ្លេចសំរែករបស់ជនរងគ្រោះឡើយ»។

២-ព្រះអង្គជះព្រះពិរោធ និង ការវិនិច្ឆ័យទៅលើជនដែលបង្ហូរឈាមជនស្លូតត្រង់៖

-អំពើបាបនៃការសម្លាប់ជនស្លូតត្រង់នៅក្រុងយេរ៉ូសាឡឹមរបស់ព្រះបាទម៉ាណាសេ(៦៩៧-៦៤៣មគស) គឺធ្ងន់ធ្ងរណាស់ ទោះបីជាទ្រង់បានយកបុត្រារបស់ខ្លួនមកដុតជាយញ្ញបូជាក្ដី(១ពង្សាវតាក្សត្រ ២១.៦) ក៏ព្រះពិរោធដ៏ខ្លាំងរបស់ព្រះជាម្ចាស់មិនរលត់សោះឡើយ ព្រះអង្គបានបញ្ជូលទ័ពបួនកងពលឲ្យមកច្បាំងទាស់នឹងសាសន៍យូដាដើម្បីបំផ្លាញពួកគេបង់ ដោយព្រោះព្រះបាទម៉ាណាសេបានសម្លាប់មនុស្សស្លូតត្រង់អស់ជាច្រើននាក់។

គម្ពីរ ២ពង្សាវតាក្សត្រ ២៤.២-៤ [២] គ្រានោះ**ព្រះអម្ចាស់**ចាត់ពួកចោរព្រៃ ជាជនជាតិខាល់ដេដេ ជនជាតិស៊ីរី ជនជាតិម៉ូអាប់ និងជនជាតិអាំម៉ូន ឲ្យប្រឆាំងនឹងព្រះបាទយេហូយ៉ាគីម។ ព្រះអង្គចាត់ពួកគេឲ្យមកបំផ្លាញស្រុកយូដាស្របតាមព្រះបន្ទូលដែលព្រះអង្គបានថ្លែងតាមរយៈពួកព្យាការី ជាអ្នកបម្រើរបស់ព្រះអង្គ។[៣] **ព្រះអម្ចាស់**ធ្វើឲ្យទុក្ខវេទនាទាំងនេះកើតមានដល់ស្រុកយូដា ដើម្បីបណ្ដេញពួកគេចេញឆ្ងាយពីព្រះភក្ត្ររបស់ព្រះអង្គ ព្រោះតែអំពើបាបទាំងប៉ុន្មាន ដែលព្រះបាទម៉ាណាសេបានប្រព្រឹត្ត[៤] ហើយទ្រង់ក៏បានបង្ហូរឈាមជនស្លូតត្រង់ពាសពេញក្រុងយេរូសាឡឹមដែរ។ ដូច្នេះ **ព្រះអម្ចាស់**មិនសព្វព្រះហឫទ័យអត់ទោសឲ្យឡើយ»។

ច្រើនទសវត្សក្រោយមក គឺនៅជំនាន់លោកអេសេគាល (៦២០-៥៧០មគស) គេបានបន្តប្រព្រឹត្តអំពើបាបរហូតទាល់តែព្រះជាម្ចាស់វិនិច្ឆ័យទោសទាស់នឹងក្រុងយេរ៉ូសាឡឹម ពួកគេត្រូវខ្មាំងសត្រូវកៀរជាឈ្លើយសឹកនាំយកទៅក្រុងបាប៊ីឡូន (៦០៥មគស)។ មានអំពើបាបជាច្រើនប្រភេទដែលគេបានប្រព្រឹត្ត ក្នុងចំណោមនោះក៏មានពិរុទ្ធភាពនៃការសម្លាប់ជនស្លូតត្រង់ផងដែរ។

គម្ពីរអេសេគាល ២២.៣ «[៣] ចូរពោលថា**ព្រះជាអម្ចាស់**មានព្រះបន្ទូលដូចតទៅ: ដោយប្រជាជននៅក្រុងនេះកាប់សម្លាប់គ្នា និងធ្វើឲ្យខ្លួនសៅហ្មង ព្រោះតែគោរពព្រះក្លែងក្លាយដែលពួកគេបានសូន ថ្ងៃកំណត់របស់ពួកគេមកដល់ហើយ»។

ព្រះជាម្ចាស់ព្រមានអំពីទុក្ខវេទនា សម្រាប់អស់អ្នកដែលបង្ហូរឈាមជនស្លូតត្រង់ ដើម្បីបានលាភសក្ការៈផ្ទាល់ខ្លួន។

- យ៉ាកុប ៥.១-៦ «[១] ចំពោះអ្នកមានវិញ ចូរស្រែកទ្រហោយំទៅ ព្រោះទុក្ខលំបាកនឹងកើតមានដល់អ្នករាល់គ្នាជាពុំខាន! [២] ទ្រព្យសម្បត្តិរបស់អ្នករាល់គ្នារលួយអស់ ហើយសម្លៀកបំពាក់របស់អ្នករាល់គ្នាក៏ត្រូវកណ្ដៀរស៊ីដែរ។ [៣] មាសប្រាក់របស់អ្នករាល់គ្នាត្រូវច្រែះស៊ី ហើយច្រែះនេះធ្វើជាបន្ទាល់ទាស់នឹងអ្នករាល់គ្នា ព្រមទាំងស៊ីសាច់អ្នករាល់គ្នា ដូចភ្លើងឆេះសុសដែរ។ គ្រានេះ ជាគ្រាចុងក្រោយបំផុត អ្នករាល់គ្នាបានប្រមូលទ្រព្យសម្បត្តិទុក [៤] ឥតបើកប្រាក់ឈ្នួលឲ្យពួកកម្មករដែលច្រូតកាត់ ក្នុងស្រែរបស់អ្នករាល់គ្នាឡើយ មើល៍! សំរែកអ្នកច្រូតទាំងនោះបានលាន់ទៅដល់ព្រះអម្ចាស់នៃពិភពទាំងមូល*។ [៥] អ្នករាល់គ្នារស់នៅលើផែនដីនេះយ៉ាងសម្បូណ៌សប្បាយ ថ្កុំថ្កើងរុងរឿង ហើយអ្នករាល់គ្នាបំពេញចំណង់ចិត្តខ្លួនយ៉ាងឆ្អែតស្កប់ស្កល់ ដូចនៅថ្ងៃដែលគេសម្លាប់សត្វ។ [៦] អ្នករាល់គ្នាបានដាក់ទោស និងប្រហារជីវិតមនុស្សសុចរិត តែគេពុំបានប្រឆាំងតបតនឹងអ្នករាល់គ្នាវិញឡើយ»។

៣-ព្រះជាម្ចាស់នៅឆ្ងាយពីមនុស្សបង្ហូរឈាម ព្រះអង្គមិនស្ដាប់ពាក្យអធិស្ឋានរបស់គេ រហូតទាល់តែគេអធិស្ឋានដោយ កែប្រែចិត្តគំនិត។

- អេសាយ ៥៩.២ «តាមពិតគឺអំពើអាក្រក់របស់អ្នករាល់គ្នាទេតើដែលខណ្ឌអ្នករាល់គ្នាពីព្រះរបស់អ្នករាល់គ្នាអំពើបាបរបស់អ្នករាល់គ្នាធ្វើឲ្យព្រះអង្គលាក់ព្រះភក្រ្តមិនព្រមស្ដាប់ឮពាក្យរបស់អ្នករាល់គ្នា»។
- អេសាយ ១.១៥-១៧ «[១៥] កាលណាអ្នករាល់គ្នាលើកដៃប្រណម្យ យើងងាកមុខចេញទោះបីអ្នករាល់គ្នាអធិស្ឋានច្រើនយ៉ាងណាក្ដីក៏យើងមិនព្រមស្ដាប់ដែរព្រោះដៃអ្នករាល់គ្នាប្រឡាក់ដោយឈាម។ [១៦] ចូរលាងសំអាត និងជំរះខ្លួនឲ្យបានស្អាតបរិសុទ្ធ! ចូរយកអំពើទុច្ចរិតចេញពីមុខយើងទៅ កុំប្រព្រឹត្តអំពើអាក្រក់ទៀតឡើយ! [១៧] ចូររៀនធ្វើអំពើល្អ! ចូរស្វែងរកយុត្តិធម៌!ចូរណែនាំអ្នកដែលសង្កត់សង្កិនគេ ឲ្យដើរតាមមាគ៌ាដ៏ត្រឹមត្រូវ! ចូររកយុត្តិធម៌ឲ្យក្មេងកំព្រាហើយការពារស្ត្រីមេម៉ាយ!» (មានពរហើយអស់អ្នកដែលស្ដាបតាម (១៨-២០)។

តើប្រជារាស្ត្ររបស់ព្រះជាម្ចាស់ឆ្លើយតបដោយរបៀបណាចំពោះការបង្ហូរឈាមជនស្លូតត្រង់? ការបង្ហូរឈាមជនស្លូតត្រង់ ដោយផ្ទាល់ ជាការបំពានច្បាប់អវិជ្ជមានរបស់ព្រះដែលថា «កុំសម្លាប់មនុស្សឲ្យសោះ» ។ ការឃើញជនស្លូតត្រង់ត្រូវគេសម្លាប់ដោយចេតនា ហើយមិនមានលទ្ធភាពការពារជាការបំពានច្បាប់វិជ្ជមានរបស់ព្រះជាម្ចាស់ដែលថា «ត្រូវស្រឡាញ់អ្នកដទៃឲ្យបានដូចស្រឡាញ់ខ្លួនឯង»។

អ្នកសម្លាប់ផ្ទាល់ និង អ្នករៀបចំសកម្មភាពផ្សេងៗដើម្បីធ្វើឲ្យនរណាម្នាក់ស្លាប់ គឺមានទោសល្មើសច្បាប់របស់ព្រះជាម្ចាស់ដូចគ្នា។ ព្រះជាម្ចាស់ណែនាំប្រជារាស្ត្ររបស់ព្រះអង្គ ឲ្យឆ្លើយតបចំពោះឃាតករដោយធ្វើយ៉ាងណាឲ្យគេទទួលស្គាល់កាតព្វកិច្ចសីលធម៌ក្នុងការធ្វើតាមច្បាប់ទាំងពីរ ពោលគឺច្បាប់វិជ្ជមាននិងច្បាប់អវិជ្ជមាន។

ក្នុងគម្ពីរចោទិយកថា ២១.១-៩ ព្រះជាម្ចាស់បង្ហាញជនជាតិអ៊ីស្រាអែលជាប្រជារាស្ត្ររបស់ព្រះអង្គ ពីរបៀបដែលគេត្រូវឆ្លើយតបចំពោះអ្នកបង្ហូរឈាមជនស្លូតត្រង់ ក្នុងករណីរកឃើញជនរងគ្រោះ ដែលឃាតករបានសម្លាប់។ ខាងក្រោមនេះ ជាអ្វីដែលព្រះជាម្ចាស់នាំប្រជារាស្ត្ររបស់ព្រះអង្គឲ្យអនុវត្ត និងពីមូលហេតុនៃការនោះផង ៖

ក-២២ «ពួកព្រឹទ្ធាចារ្យ និងពួកចៅក្រម ត្រូវវាស់ចម្ងាយពីកន្លែងសាកសពនោះ ទៅក្រុងនានាដែលនៅជុំវិញ»។ ការវាស់វែងជាការបង្កើតដែនសមត្ថកិច្ច យុត្តាធិការ (ការកំណត់មុខសញ្ញា)។ អ្នកណានៅជិតជាងអ្នកនោះទទួលខុសត្រូវច្រើនជាង។ ការរំលឹកមួយឲ្យ «ស្រឡាញ់អ្នកជិតខាងរបស់ខ្លួន»។



ខ-២៣-៦ «[៣] កាលដឹងថា ក្រុងណាមួយនៅជិតសាកសពជាងគេ ពួកព្រឹទ្ធាចារ្យរបស់ក្រុងនោះត្រូវយកគោ
ញីស្ទាវមួយមក គឺគោដែលគេពុំធ្លាប់ទឹម ឬប្រើឲ្យធ្វើការនៅឡើយ។ [៤] ពួកព្រឹទ្ធាចារ្យរបស់ទីក្រុងត្រូវនាំគោ
ញីស្ទាវនោះចុះទៅកាន់ជ្រោះមួយ ដែលមានទឹកហូរមិនចេះរីង ហើយជាកន្លែងគ្មាននរណាសាបព្រោះ ឬ
ដាំដំណាំទេ។ គេត្រូវវាយបំបាក់កគោញី នៅក្នុងជ្រោះ។ [៥] ពេលនោះ ពួកបូជាចារ្យ*ពីកុលសម្ព័ន្ធ*លេវីនាំ
គ្នាចូលមក - **ព្រះអម្ចាស់** ជាព្រះរបស់អ្នក បានជ្រើសរើសពួកបូជាចារ្យឲ្យនៅបម្រើព្រះអង្គ និងឲ្យពរប្រជា
ជន ក្នុងព្រះនាមព្រះអង្គ។ ពេលប្រជាជនមានជម្លោះ ឬវាយតប់គ្នារហូតដល់របួស ក៏ពួកបូជាចារ្យមានមុខ
ងារអារកាត់រឿងរ៉ាវរបស់ពួកគេដែរ។ [៦] ព្រឹទ្ធាចារ្យរបស់ក្រុងដែលនៅជិតសាកសព ត្រូវនាំគ្នាលាងដៃពីលើ
គោញី ដែលគេវាយបំបាក់កនៅក្នុងជ្រោះ»។

គ-២៧-៩ «[៧] ទាំងប្រកាសថា “យើងខ្ញុំពុំបានធ្វើឃាតជនរងគ្រោះនេះទេ ហើយយើងខ្ញុំក៏ពុំបានឃើញ
នរណាធ្វើឃាតគេដែរ។ [៨] **ព្រះអម្ចាស់**អើយ សូមលើកលែងទោសអ៊ីស្រាអែល ដែលជាប្រជារាស្ត្ររបស់
ព្រះអង្គ ឲ្យរួចពីបាបផង។ សូមកុំឲ្យអ៊ីស្រាអែលជាប្រជារាស្ត្រដែលព្រះអង្គបានរំដោះ ត្រូវទទួលទោស
ព្រោះឃាតកម្មទៅលើជនស្លូតត្រង់នេះឡើយ”។ ធ្វើដូច្នេះ ពួកគេនឹងគ្មានទោស ព្រោះតែឃាតកម្មនេះ
ទេ។ [៩] រីឯអ្នកវិញ ត្រូវលុបបំបាត់ការសម្លាប់ជនស្លូតត្រង់ឲ្យអស់ពីចំណោមអ្នក ហើយប្រព្រឹត្តតែអំពើត្រឹម
ត្រូវដែលគាប់ព្រះហឫទ័យ**ព្រះអម្ចាស់**»។

ពិធីដ៏មានតម្លៃ ផ្តល់នូវវិធីសាស្ត្រសម្រាប់មនុស្សដែលមានអារម្មណ៍បាត់បង់ ដើម្បីកំណត់សកម្មភាពអសីលធម៌។ មានការខាតបង់ខាងសេដ្ឋកិច្ច (គោញីដែលមិនមានអ្នកទឹម និងបាត់បង់ការងារ) និងការកោះប្រជុំធំកើតឡើង ពួកគេមានអារម្មណ៍ដែលគេមិនធ្លាប់មានពីមុនដែលជាមនោសញ្ចេតនានៃការបាត់បង់ជីវិតមនុស្សលោក។ សម្រាប់ពួកគេ ជនរងគ្រោះនោះជាមនុស្សប្លែកមុខ ហើយនឹកក្នុងចិត្តថា ៖«វាមិនទាក់ទងនឹងខ្ញុំទេ»។ ប៉ុន្តែជនរងគ្រោះនោះមិនមែនជាមនុស្សប្លែកមុខនៅចំពោះព្រះជាម្ចាស់ឡើយ។ ការស្លាប់នោះមិនជាប់ពាក់ព័ន្ធនឹងពួកគេក៏ពិតមែន។ ការនោះនឹងធ្វើឲ្យចិត្តរបស់គេទៅជារឹង។ តាមរយៈការតម្រង់ទិសអ្នកដឹកនាំបែបនេះ ព្រះជាម្ចាស់ជួយប្រជារាស្ត្រព្រះអង្គឲ្យ ៖

-មានអារម្មណ៍បាត់បង់សភាវៈជាមនុស្សលោក ដែលពួកគេមិនស្គាល់ តែព្រះអង្គស្គាល់។
-រៀនឲ្យតម្លៃដល់ជីវិតតាមរយៈការស្តាប់បង្គាប់តាមច្បាប់របស់ព្រះជាម្ចាស់ដែលការពារជីវិត និងសុខមាលភាពមនុស្ស។
-ព្រះជាម្ចាស់តម្រង់អ្នកដឹកនាំឲ្យមានទំនួលខុសត្រូវ ជំនួសសហគមន៍ទាំងមូល។
ព្រះជាម្ចាស់បានតែងតាំងឲ្យមានអ្នកដឹកនាំ *ដឹកនាំ* ប្រជាជនឲ្យចាប់យកវិបត្តិសីលធម៌ជាធំ *ការបង្ហូរឈាមជនស្លូតត្រង់* ដើម្បីបញ្ជាក់ជាថ្មីពីតាំងចិត្តស្តាប់បង្គាប់តាមច្បាប់របស់ព្រះជាម្ចាស់ (ទាំងពីរ គឺច្បាប់បែបអវិជ្ជមាន និង វិជ្ជមាន) ហើយនាំឲ្យស្វែងរកការលើកលែងទោសរបស់ព្រះជាម្ចាស់។ ព្រឹទ្ធាចារ្យ...ប្រកាសថា “យើងខ្ញុំពុំបានធ្វើឃាតជនរងគ្រោះនេះទេ ហើយយើងខ្ញុំក៏ពុំបានឃើញនរណាធ្វើឃាតគេដែរ។...រីឯអ្នកវិញ

ត្រូវលុបបំបាត់ការសម្លាប់ជនស្លូតត្រង់ឲ្យអស់ពីចំណោមអ្នក ហើយប្រព្រឹត្តតែអំពើត្រឹមត្រូវដែលគាប់ព្រះហឫទ័យព្រះអម្ចាស់»ចោទិយកថា ២១.៦-៩)។

## តើព្រះជាម្ចាស់មានទស្សនៈបែបណាចំពោះការសម្លាប់ទារក /ការរំលូតកូន និងការព្រងើយកន្តើយចំពោះការ សម្លាប់ទារក/ការរំលូតកូន?

១-ការយកទារកទៅបូជាយញ្ញ ឬការសម្លាប់ទារកគ្មានកំហុសដោយចេតនា ជាការដែលព្រះជាម្ចាស់មិនគាប់ព្រះហឫទ័យ ហើយទ្រង់ព្រះពិរោធ។ ឯការមិនអើពើរចំពោះឃាតកម្មលើទារក ដោយនិយាយថា «មិនមែនជារឿងរបស់ខ្ញុំផង» គឺដូចគ្នានឹងការប្រមាថព្រះជាម្ចាស់ដែរ។

គម្ពីរលេវីវិន័យ ២០.២-៥ «[២] «ចូរប្រាប់ជនជាតិអ៊ីស្រាអែលថា: ក្នុងចំណោមជនជាតិអ៊ីស្រាអែល ឬក្នុងចំណោមជនបរទេសដែលរស់នៅក្នុងស្រុកអ៊ីស្រាអែល បើនរណាម្នាក់ប្រគល់កូនចៅរបស់ខ្លួនទៅឲ្យគេបូជាសែនព្រះម៉ូឡុក អ្នកនោះត្រូវទទួលទោសដល់ស្លាប់ គឺប្រជាជននៅក្នុងស្រុកត្រូវយកដុំថ្មគប់សម្លាប់អ្នកនោះ។ [៣] រីឯយើង យើងនឹងដាក់ទោសបុរសនោះ យើងនឹងដកគេចេញពីចំណោមប្រជាជនរបស់ខ្លួន ព្រោះគេបានប្រគល់កូនចៅរបស់ខ្លួនទៅឲ្យព្រះម៉ូឡុក ជាហេតុបណ្ដាលឲ្យទីសក្ការៈរបស់យើងទៅជាសៅហ្មង ហើយបង្អាប់បង្អោននាមដ៏វិសុទ្ធរបស់យើងទៀតផង។ [៤] ប្រសិនបើប្រជាជននៅក្នុងស្រុកធ្វើមិនដឹងមិនឮអំពីរឿងបុរស ដែលប្រគល់កូនចៅទៅឲ្យព្រះម៉ូឡុក គឺពួកគេមិនព្រមសម្លាប់បុរសនោះទេ [៥] យើងនឹងដាក់ទោសបុរសនោះ ព្រមទាំងអំបូររបស់គេផង។ យើងនឹងដកគេចេញពីចំណោមប្រជាជនរបស់ខ្លួន ហើយយើងក៏ដកអស់អ្នកដែលក្បត់យើងទៅគោរពព្រះម៉ូឡុក ដូចអ្នកនោះដែរ»។

២-គ្រប់ទាំងជីវិតឥតទោសរបស់មនុស្សលោក ព្រះជាម្ចាស់ផ្ដល់តម្លៃ ហើយសព្វព្រះទ័យឲ្យគេបានទទួលការការពារ។

- ម៉ាថាយ ១៨.៥-៦ «[៥] អ្នកណាទទួលក្មេងតូចណាម្នាក់ដូចក្មេងនេះ ក្នុងនាមខ្ញុំ ក៏ដូចជាបានទទួលខ្ញុំដែរ [៦] អ្នកណានាំអ្នកតូចតាចម្នាក់ក្នុងបណ្ដាអ្នកដែលជឿលើខ្ញុំនេះ ឲ្យប្រព្រឹត្តអំពើបាប ចំពោះអ្នកនោះប្រសិនបើគេយកត្បាល់ថ្មយ៉ាងធំមកចងកគាត់ ទម្លាក់ទៅក្នុងបាតសមុទ្រឲ្យលង់ទឹក ប្រសើរជាងទុកគាត់ឲ្យនៅរស់»។

៣-ព្រះជាម្ចាស់ទតឃើញការយកទារកទៅបូជាយញ្ញ ដូចជាការសម្លាប់បុត្រផ្ទាល់របស់ព្រះអង្គ ។

- អេសេគាល ១៦.២០-២១ «[២០] នាងពុំស្កប់ចិត្តនឹងអំពើពេស្យាចារទេ គឺនាងបានយកកូនប្រុសកូនស្រីដែលនាងបានបង្កើតឲ្យយើង ទៅធ្វើយញ្ញបូជាដល់រូបទាំងនោះទៀតផង! [២១] នាងបានអារ កកូនប្រុសរបស់យើង ហើយដុតថ្វាយរូបទាំងនោះ»។

៤-ការយកកុមារទៅបូជាយញ្ញ ជាការដ៏អាក្រក់ដែលព្រះជាម្ចាស់ទ្រង់មិនដែលនឹកឃើញទ្រង់ហៅថាជាអំពើព្រៃផ្សៃ។

- យេរេមា ៣២.២៥ «ពួកគេបានសង់កន្លែងសក្ការៈនៅទួលខ្ពស់សំរាប់ព្រះបាល ក្នុងជ្រលងភ្នំហ៊ីនណូមដើម្បីយកកូនប្រុសកូនស្រីរបស់ខ្លួន ទៅសែនព្រះម៉ូឡុក ដោយដុតទាំងរស់។ យើងពុំដែលបង្គាប់ឲ្យគេធ្វើអំពើបែបនេះសោះ យើងក៏មិនដែលនឹកឃើញអំពីការនេះដែរ គឺធ្វើឲ្យជនជាតិយូដាមានទោសព្រោះតែអំពើព្រៃផ្សៃ»។

## តើការរំលូតកូន ការថ្វាយកូនក្មេងជាបូជាយញ្ញមែនទេ?

មែនហើយ ការយកកូនក្មេងទៅបូជាយញ្ញគឺពិតជាក្រៅទស្សនសាសនានិយមមែន។ ទាំងពីរហ្នឹងជាប់ទាក់ទង ៖

- ឪពុកម្តាយមានចេតនាក្នុងការសម្លាប់កូនខ្លួនឯង
- ការសម្លាប់ដោយដុតទាំងរស់ ឬកាត់ជាផ្នែកៗ
- ការយកជីវិតមនុស្សទៅដោះដូរ(ឬបូជា)នឹងអ្វីផ្សេងទៀត

នៅសម័យបុរាណ គេយកកូនក្មេងទៅបូជាយញ្ញដើម្បីចៀសវាងភាពអវិជ្ជមានមួយចំនួនដូចជា គ្រោះរាំងស្ងួត គ្រោះទុរ្ភិក្ស ឬជាសំណែនដល់ព្រះនានាដើម្បីឈ្នះសង្គ្រាម។ បច្ចុប្បន្នេះ ការយកកូនក្មេងទៅបូជាយញ្ញដល់ព្រះនានាលែងមានទៀតហើយ ប៉ុន្តែមនុស្សលោកបានសម្រេចចិត្តរំលូតកូនរបស់ខ្លួនឯង *ដើម្បីចៀសវាងភាពអវិជ្ជមាន* មួយចំនួនដូចជា បំបាត់ភាពអាម៉ាស ការខ្មាស់អៀន គ្របបាំងអំពើបាបនៃការប្រាសចាកសីលធម៌ផ្លូវភេទ បន្ទុកហិរញ្ញវត្ថុលំបាក ឬ *ដើម្បីបានសម្រេចដូចអ្វីដែលគេប៉ងប្រាថ្នា* ដូចជា សញ្ញាប័ត្រ ជម្រើសចង់បានកូនប្រុស (តែទារកក្នុងផ្ទៃជាកូនស្រី) ចង់បានកូនដែលមានសុខភាពល្អ (តែទារកក្នុងផ្ទៃមានពិការភាព ឬខុសប្រក្រតី) ដើម្បីលុយ ឬផ្គាប់ចិត្តនរណាម្នាក់។ សេចក្តីពិតដ៏ឈឺចាប់បំផុត ដែលមនុស្សយើងសម្រេចចិត្តរំលូតកូន គឺថា យើងសុខចិត្តលះបង់កូនរបស់ខ្លួនឯង ដើម្បីដេញតាមរបស់ដែលមានតម្លៃថោកជាងកូនរបស់ខ្លួន។

ពាក្យថា រំលូតកូន ពុំមានក្នុងព្រះគម្ពីរ ដូចពាក្យសម័យថ្មីនេះទេ។ ប៉ុន្តែ យើងដឹងថា ព្រះជាម្ចាស់ហាមឃាត់ការរំលូតកូន ព្រោះព្រះអង្គហាមឃាត់ការសម្លាប់ជីវិតមនុស្ស (ចោទិយកថា ៥.១៧) ការសម្លាប់មនុស្សឥតទោស ឬជនស្លូតត្រង់ដោយចេតនា។ បើទារកក្នុងផ្ទៃជាមនុស្សលោក ឯយើងវិញក៏បានដឹងច្បាស់ថា ទារកនោះជាមនុស្សពិត តែយើងនៅតែធ្វើការរំលូតចេញ គឺមានន័យថាជាការសម្លាប់ទារកឥតទោសដោយចេតនា។ សូមមើលវីដេអូពីការរំលូតកូនក្នុងតំណរភ្ជាប់ខាងក្រោមនេះ www.baovemamsong.org/media។ សូមរំលឹកថា វីដេអូរនេះ អាចប៉ះពាល់អារម្មណ៍យើងខ្លាំង។ លោកអ្នកអាចបិទភ្នែក ឬងាកមុខចេញក៏បាន ប៉ុន្តែយើងលើកទឹកចិត្តលោកអ្នកឲ្យមើលឲ្យច្បាស់នឹងភ្នែកពីទិដ្ឋភាពនៃការរំលូតកូនតើវាយ៉ាងណា ហើយអនុញ្ញាតិឲ្យព្រះជាម្ចាស់ធ្វើការក្នុងចិត្តលោកអ្នក។ បន្ទាប់ពីយើងបង្ហាញវីដេអូរនេះហើយ សូមកុំអាលទៅណា ចំណាយពេលអធិស្ឋាន ទួញសោក និង សារភាពទៅចំពោះព្រះជាម្ចាស់។

## នេះជាការរំលូតកូន

វីដេអូរទី១

លោកវេជ្ជបណ្ឌិត ឡេវ៉ាទីណូ ពន្យល់ពីនិតិវិធីរំលូតកូននៅត្រីមាសទី២ (មានរយៈពេល ៤នាទី)។

វីដេអូរទី២

សកម្មភាពនៃការរំលូតកូន។ វីដេអូរបង្ហាញពីភាពសាហាវឃោរឃៅពិតៗនៃការរំលូតកូន (មានរយៈពេល២នាទី) *សូមស្កែន QR ស្វែងរកវីដេអូរនេះមាតិការវីដេអូរ នេះមិនសម្រាប់កុមារទេ)។*



តើការវះកាត់យកកូនក្រៅស្បូន ជាអ្វីដែរ? តើនេះជាទិដ្ឋភាពមួយផ្សេងទៀតនៃការរម្លូតកូនមែនទេ? មិនមែនទេ។

ការ មានកូនក្រៅស្បូន គឺដោយសារគភ៌ដែលជាអំព្រីយ៉ុងជីវិតតោងជាប់នឹងដៃស្បូន ឬនៅកន្លែងផ្សេងទៀតដែលមិនមែន នៅក្នុងស្បូន។ គភ៌នោះមិនអាចមានជីវិតបាន ឡើយ ហើយបើសិនជាមិនយកចេញទេ ប្រាកដជានឹងត្រូវប៉ះពាល់ដល់ជីវិតរបស់ម្តាយជាមិនខានឡើយ។




សូមចាំថា ការរម្លូតកូន ជាការសម្លាប់ទារកក្នុងផ្ទៃដោយចេតនា។ ឯការវះកាត់យកកូនក្រៅស្បូន ជាការសង្គ្រោះជីវិតម្តាយ ស្របពេលដែលដឹងជាមុនថា ទារកក្រៅស្បូននោះមិនអាចរស់បាន។ ការវះកាត់យកទារកក្រៅស្បូនជាការសង្គ្រោះជីវិតម្តាយ មិនមែនជាការសម្លាប់ទារកនោះទេ។ បើសិនជាទៅអនាគត ផ្នែកវេជ្ជសាស្រ្តជឿនលឿនខ្លាំងអាចបង្វែរគភ៌ដែលនៅក្រៅស្បូនឲ្យមកនៅក្នុងស្បូនវិញបាន នោះជារឿងត្រឹមត្រូវដែលត្រូវធ្វើដូច្នោះ។

## សំណួរទី៣ ៖ តើយើងនាំព្រះគុណនៃដំណឹងល្អទៅដលពិរុទ្ធជននៃការរម្លូតកូន ដើម្បីឲ្យគេបានទទួលការលើកលែងទោស និង មានសេរីភាព ដោយរបៀបណា?

ការលាក់បាំងអំពើបាប និងពិរុទ្ធភាព ការធ្វើមិនដឹងមិនឮ ជាចោរលួចការពិសោធន៍នូវព្រះគុណ និង សេរីភាពរបស់ព្រះជាម្ចាស់ដែលមានសម្រាប់ខ្លួនយើង។

ការពិសោធន៍អំពីព្រះគុណរបស់ព្រះជាម្ចាស់ គឺបានមកពី ការទទួលការលើកលែងទោស និង ការពិសោធន៍នៃការសម្អាតមនសិការដែលមកពីព្រះជាម្ចាស់ ដែលប្រោសលោះឲ្យរួចពីអាថ៌កំបាំងអំពើបាប និងភាពអៀនខ្មាស និងវិប្បដិសារីដែលលាក់បាំង ហើយបង្វែរទៅជា ទីបន្ទាល់ដោយបើកចំហរ និង ដោយអំណរ នៃព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងវិញ។ ការផ្លាស់ប្រែដែលកើតឡើងភ្លាមៗ ឬកើតឡើងបន្តិចម្តងៗ ត្រូវតែកើតចេញពីជំនឿ។

ដំណាក់កាលបីយ៉ាងដើម្បីចាកចេញការលាក់ពិរុទ្ធភាព ទៅរកការបើកចំហរពិរុទ្ធភាព (ទំនុកតម្កើង ៣២.១-៥ អេសាយ ៥៣.៤-៦ ហេព្រើ ៩.១៤)។

១-ទំនុកតម្កើង ៣២.១-៥ យើងត្រូវការជំនឿនៃការសារភាពដោយបើកចំហរ និង ការកែប្រែចិត្តគំនិត។

តើយើងពិសោធន៍នូវពិរុទ្ធភាពដោយរបៀបណា? យើងមានចេតនាចង់បិទ ឬគ្របបាំង ដូចព្រះបាទដាវីឌ (ខ៣)។ ប៉ុន្តែ ការនៅស្ងៀមធ្វើឲ្យយើងកាន់តែខ្សោយទៅៗ (ខ៣)។ ពិរុទ្ធភាពធ្វើឲ្យយើងមានអារម្មណ៍ដូចទូលភ្នំមួយតែម្នាក់ឯង។ ទុក្ខសោក ភាពអៀនខ្មាស និងទម្ងន់វិប្បដិសារី (ខ៤)។ ប៉ុន្តែ ការបើកចំហរ ឬការសារភាពបាបរបស់លោកអ្នក (ខ៥) គឺព្រះជាម្ចាស់អាចលើកលែងទោស និងធ្វើការដោះលោកអ្នកឲ្យមានសេរីភាពក្នុងជីវិតរបស់លោកអ្នកបាន។ ព្រះពរ ភាពរីករាយ និង សេរីភាព គឺមានសម្រាប់អស់អ្នកដែលចាកចេញពីពិរុទ្ធភាពទៅរកព្រះគុណ(ខ១)។

**ដោយសារជំនឿ ៖**

ក)-យល់ព្រមជាមួយព្រះជាម្ចាស់ថា អ្វីដែលលោកអ្នកបានធ្វើជាអំពើអាក្រក់ ហើយព្រះជាម្ចាស់មានសិទ្ធិដាក់ទោសលោកអ្នក។ ទំនុកតម្កើង ៥១.៣-៤ « [៣] ទូលបង្គំទទួលសារភាពថា ទូលបង្គំបានធ្វើខុសហើយ អំពើបាបរបស់ទូលបង្គំជិតជាប់នៅក្នុងអារម្មណ៍ទូលបង្គំជានិច្ច។ [៤] ទូលបង្គំបានប្រព្រឹត្តអំពើបាបទាស់នឹងព្រះហឫទ័យ ព្រះអង្គ គឺទាស់នឹងព្រះអង្គតែមួយគត់ ដ្បិតទូលបង្គំបានប្រព្រឹត្តអំពើមួយ ដែលព្រះអង្គចាត់ទុកថាជាអំពើអាក្រក់។ ទោះបីព្រះអង្គកាត់ទោសទូលបង្គំយ៉ាងណាក្ដី ក៏ព្រះអង្គនៅតែសុចរិត ហើយទោះបីព្រះអង្គធ្វើទោសទូលបង្គំយ៉ាងណាក្ដី ក៏ព្រះអង្គនៅតែឥតកំហុសដដែល»។

ខ)-**សារភាពអំពើបាប**របស់លោកអ្នក ហើយទូលសូមព្រះជាម្ចាស់លើកលែងទោសឲ្យលោកអ្នក។ ព្រះបាទដាវីឌ «កាន់តែរីងរៃទៅៗ»។ ទំនុកតម្កើង ៣២.៣-៥ «[៣] ដរាបណាទូលបង្គំមិនសារភាពកំហុសទេនោះ ទូលបង្គំកាន់តែរីងរៃទៅៗ ទូលបង្គំថ្ងូរជារៀងរាល់ថ្ងៃ[៤] ដ្បិតព្រះអង្គធ្វើទោសទូលបង្គំទាំងថ្ងៃទាំងយប់កម្លាំងទូលបង្គំខ្សោះល្ហើយដូចទឹករីងស្ងួតនៅរដូវប្រាំង។ [៥] ទូលបង្គំបានសារភាពអំពើបាបចំពោះព្រះអង្គ ទូលបង្គំមិនបានលាក់លៀមកំហុសរបស់ទូលបង្គំឡើយ ទូលបង្គំពោលថា«ខ្ញុំនឹងទទួលសារភាពអំពើបាបរបស់ខ្ញុំចំពោះ**ព្រះអម្ចាស់**!» ព្រះអង្គក៏លើកលែងទោសទូលបង្គំឲ្យរួចពីបាប»។

គ)-**អេសាយ ៥៣.៤-៦** យើងត្រូវការជំនឿក្នុងទម្រង់នៃការទុកចិត្តលើព្រះគ្រិស្ត និងឈើឆ្កាង។ តើព្រះជាម្ចាស់អាចលើកលែងទោសដល់ខ្ញុំដោយផ្អែកលើមូលដ្ឋានអ្វីខ្លះ? វាជារឿងអយុត្តិធម៌ដែលសម្រេចឲ្យមនុស្សជាប់ពិរុទ្ធរួចពីពិរុទ្ធភាព ឬទោសទណ្ឌចំពោះការសម្លាប់ជនស្លូតត្រង់ ប៉ុន្តែព្រះជាម្ចាស់ អាចប្រទានទានសេចក្ដីមេត្តាដល់យើងបាន ក៏ព្រោះតែព្រះអង្គបានដាក់ទោសទណ្ឌរបស់យើងទាំងអស់ទៅលើអង្គព្រះគ្រិស្តរួចហើយ។ យើងសមនឹងស្លាប់ក្នុងអំពើបាបខ្លាំងណាស់ «ដ្បិតលទ្ធផលនៃអំពើបាប គឺជាសេចក្ដីស្លាប់... (រ៉ូម ៦.២៣) ប៉ុន្តែ ព្រះយេស៊ូស្ម័គ្រព្រះទ័យសុគតនៅត្រង់កន្លែងរបស់យើង។ ព្រះជាម្ចាស់បានប្រទានព្រះយេស៊ូ (ដែលគ្មានបាបសោះ) មកជំនួសទណ្ឌកម្មនៃអំពើបាបរបស់យើង ដើម្បីលើកតម្កើងសេចក្ដីយុត្តិធម៌របស់ព្រះជាម្ចាស់ ស្របពេលដែលព្រះអង្គបង្ហូរសេចក្ដីមេត្តាករុណាដល់មនុស្សលោក។

ព្រះយេស៊ូបានបង់ថ្លៃបំណុលទណ្ឌកម្មនៃអំបាបយ៉ាងពេញថ្លៃតាមរយៈការសុគតរបស់ព្រះអង្គ ព្រះអង្គប្រទានការលើកលែងទោសយ៉ាងពេញលេញសម្រាប់អស់អ្នកដែលកែប្រែចិត្តគំនិត ហើយជឿទុកចិត្តលើព្រះអង្គ។ ទោះបីជាច្បាប់របស់មនុស្សក៏ដោយ ក៏មិនដាក់ទោសត្រួតគ្នានូវបទឧក្រិដ្ឋដូចគ្នានោះទេ។ ព្រះយេស៊ូបានបង់ថ្លៃបាបទាំងអស់ដើម្បីឲ្យយើងបានទទួលការលើកលែងទោសពេញលេញ ហេតុនេះហើយគ្មានអ្វីមួយនៅក្នុងជីវិតរបស់យើងដែលសមនឹងទទួលទណ្ឌកម្មទៀតឡើយ។

ក្នុងបរិបទនៃការរម្លូតកូន គឺថា ព្រះគ្រិស្តបានខ្វាយព្រះលោហិតឥតទោសរបស់ព្រះអង្គនៅលើឈើឆ្កាង ដើម្បីគ្របបាំង (ជួននឹងបាប) ពិរុទ្ធភាពនៃការបង្ហូរឈាមជនស្លូតត្រង់ ឬការមិនធ្វើអ្វីសោះដើម្បីបញ្ឈប់ការនោះរួចហើយ។

ពេលណាយើងជឿទុកចិត្តក្នុងព្រះគ្រិស្ត គឺយើងជឿទុកចិត្តថា ៖

១)-ព្រះគ្រិស្តបានសុគតបង់ថ្លៃអំពើបាបទាំងអស់របស់យើង រួមទាំងបាបដែលអាមាស់ជាងគេ ដូចជាការរម្លូតកូនជាដើម។

២)-ព្រះគ្រិស្តបានរងទុក្ខទារុណកម្ម បង់ថ្លៃជំនួសទណ្ឌកម្មទាំងអស់នៃអំពើបាបរបស់យើងម្នាក់ៗ មានទាំងការរម្លូតកូនផង។

**ដោយសារជំនឿ៖**

**១)-យើងជឿជាក់ថា** ខ្លួនឯងបានទទួលព្រះអំណោយនៃការរងទុក្ខជំនួសកន្លែងរបស់យើងនៃអង្គព្រះគ្រិស្តនៅលើឈើឆ្កាងដែលជាព្រះពិរោធរបស់ព្រះជាម្ចាស់។

- អេសាយ ៥៣.៥ « ប៉ុន្តែ លោកត្រូវគេចាក់ទម្លុះព្រោះតែការបះបោររបស់យើង លោកត្រូវគេជាន់ឈ្លីព្រោះតែអំពើទុច្ចរិតរបស់យើង លោកបានរងទារុណកម្ម ដើម្បីឲ្យយើងទទួលសេចក្តីសុខសាន្ត ហើយដោយសារស្នាមរបួសរបស់លោក យើងក៏បានជាសះស្បើយ»។
- អេភេសូ១.៧ «ដោយយើងរួមក្នុងអង្គព្រះគ្រិស្តនេះ ព្រះជាម្ចាស់បានលោះយើង ដោយព្រះលោហិតរបស់ព្រះអង្គ និងលើកលែងទោសឲ្យយើងបានរួចពីបាប ស្របតាមព្រះគុណដ៏លើសលប់របស់ព្រះអង្គ»។
- រ៉ូម ៥.៩ «ឥឡូវនេះ បើព្រះជាម្ចាស់ ប្រោសយើងឲ្យបានសុចរិតដោយសារព្រះលោហិតរបស់ព្រះគ្រិស្តយ៉ាងហ្នឹងទៅហើយ ព្រះអង្គរឹតតែសង្គ្រោះយើងឲ្យរួចពីព្រះពិរោធ ដោយសារព្រះគ្រិស្តថែមទៀតជាពុំខាន»។
- 

**២)-ហេប្រឺ ៩.១៤** យើងត្រូវការជំនឿក្នុងការស៊ូទ្រាំ និងការតយុទ្ធដើម្បីមានមនសិការស្អាតស្អំ។ ព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យពិសោធន៍នូវការជម្រះមនសិការពីពិរុទ្ធភាព និងកិច្ចការដែលបណ្តាលឲ្យស្លាប់ មកបម្រើព្រះជាម្ចាស់ដ៏មានព្រះជន្មគង់នៅវិញ។ ព្រះវិញ្ញាណរបស់ព្រះគ្រិស្ត ដោះយើងឲ្យរួចចំណងនៃមនសិការសៅហ្មងព្រមទាំងប្រទានចេស្តាឲ្យយើងមានជីវិតថ្មីក្នុងការបម្រើទ្រង់។ ប៉ុន្តែការនោះអាចកើតឡើងបានតាមរយៈជំនឿ យើងត្រូវតយុទ្ធជម្រះមនសិការសៅហ្មង និងដើម្បីសេរីភាពក្នុងការបម្រើព្រះជាម្ចាស់។

ប្រកដែលយើងដើរតាម គឺចាប់ផ្តើមពីការស្កប់ចិត្តលើការផ្តត់ផ្គង់របស់ព្រះគ្រិស្ត (ការសង្គ្រោះចំពោះបាបដែលបានប្រព្រឹត្តកន្លងមក និងការជម្រះមនសិការរបស់យើង) ហើយបន្ទាប់មក ងាកមករំលឹកខ្លួនឯងអំពីការទាំងនោះ នោះហើយជាអ្វីដែលយើងត្រូវការ។ នេះជាប្រកតែមួយគត់ ដើម្បីបានរួចខ្លួនពីពិរុទ្ធភាព និង ការប្រោសឲ្យជាពីការឈឺចាប់នៃជម្រើសនានាពីអតីតកាល។ ពេលដែលសត្រូវរបស់យើង (ពួកវិញ្ញាណអាក្រក់) ឬគំនិតខ្លួនឯង ព្យាយាមទាញនាំឲ្យយើងគិតពីបាបកន្លងមក ហើយដាក់ទោសយើង នោះយើងត្រូវដើរដោយជំនឿ និង ប្រកាសដោយក្លាហានពីការសង្គ្រោះ និងមនសិការជ្រះស្អាតដែលយើងបានទទួលតាមរយៈអង្គព្រះគ្រិស្ត។ ព្រះជាម្ចាស់សព្វព្រះហឫទ័យឲ្យយើងទុកចិត្តតង្វាយជួននឹងបាបពេញលេញរបស់ព្រះអង្គ ព្រមទាំងបម្រើព្រះអង្គដោយសេរីភាពប្រកបដោយមនសិការជ្រះស្អាត។

៣-*អនុវត្ត* ដំណឹងល្អក្នុងមនសិការផ្ទាល់របស់លោកអ្នក ហើយបែរចេញពីរុទ្ធភាពទៅរកការធ្វើបន្ទាល់ដោយចិត្តក្លាហាន។

- ហេប្រឺ ៩.១៤ «ចំណង់បើព្រះលោហិតរបស់ព្រះគ្រិស្តវិញ តើនឹងរឹតតែជំរះមនសិការយើងឲ្យបានរួចផុតពីអំពើឥតបានការ ដើម្បីគោរពបម្រើព្រះជាម្ចាស់ដ៏មានព្រះជន្មរស់ខ្លាំងយ៉ាងណាទៅទៀត? គឺដោយសារព្រះវិញ្ញាណ ដែលគង់នៅអស់កល្បជានិច្ច ព្រះគ្រិស្តបានថ្វាយព្រះអង្គផ្ទាល់ទៅព្រះជាម្ចាស់ទុកដូចជាយញ្ញបូជាឥតសៅហ្មង»។
- វិវរណៈ ១២.១១ «បងប្អូនយើងបានឈ្នះវា ដោយសារព្រះលោហិតរបស់កូនចៀម និងដោយសក្ខីភាពរបស់ពួកគេ ហើយបងប្អូនទាំងនោះបានស៊ូប្តូរជីវិត ឥតស្តាយសោះឡើយ»។

លោកអ្នកដឹងថា ខ្លួនឯងបានពិសោធន៍នូវសេរីភាព នៅពេលណាដែលលោកអ្នកបែរចេញពីការគួរឲ្យអាម៉ាស់ដែលលាក់បាំង និង ការធ្វើមិនដឹងមិនឮទៅរកការធ្វើបន្ទាល់ និងលើកតម្កើងព្រះជាម្ចាស់។ សូមមើលវីដេអូរអំពីជ័យជំនះ

តាមរយៈព្រះគុណក្នុងគេហទំព័រ www.passionlife.org.។

**អធិស្ឋាន** ចូរចំណាយពេលធ្វើយ៉ាងឲ្យមនុស្សទទួលស្គាល់អំពើបាប និងសារភាពអំពើបាបរបស់ខ្លួន។ ចូរផ្តល់ឱកាសឲ្យអស់អ្នកដែលចង់ក្រោកឈរ និងចែករំលែកបទពិសោធន៍របស់ខ្លួន។ ចូរអធិស្ឋានសម្រាប់អ្នកទាំងនោះ។ ចូរយាងព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះជាម្ចាស់ប្រទានចេស្តាផង។

## សំណួរទី ៤ ៖ តើព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យធ្វើអ្វីខ្លះ ដើម្បីបញ្ឈប់ការបង្ហូរឈាមដែលគ្មានកំហុស ហើយតើត្រូវជួយមនុស្សដែលធ្វើខុសឆ្គងដោយរបៀបណា?

ឥឡូវនេះ យើងបានចាកចេញពី *អ្វីដែលព្រះជាម្ចាស់មានព្រះបន្ទូលអំពីជីវិតមនុស្សលោក* ទៅកាន់ *អ្វីដែលព្រះជាម្ចាស់ត្រាស់ហៅយើងឲ្យការពារជីវិតមនុស្សលោក* ។
យើងនិយាយដោយសង្ខេបអំពីចរិសាស្ត្រដែលព្រះគម្ពីរទាមទាឲ្យមាន ទាក់ទងនឹងការរម្លូតកូនដូចខាងក្រោម ៖

**១)-បដិសេធន៍ការរម្លូតកូន**

ការបដិសេធន៍ការរម្លូតកូន ជាច្បាប់ទីមួយដែលត្រូវគោរពតាម «កុំសម្លាប់មនុស្ស» (និក្ខមនំ ២០.១៣)។ មិនត្រូវប៉ុនប៉ងសម្លាប់ជនស្លូតត្រង់ដោយចេតនានោះទេ ទោះជាមានបញ្ហាធំប៉ុណ្ណាក៏ដោយ ក៏នៅតែមានដំណោះស្រាយជានិច្ច។ ការរម្លូតកូន ជាការសម្លាប់ជីវិតឥតទោសដោយចេតនា។ ហេតុនេះហើយ ការរម្លូតកូន ជាជម្រើសមិនត្រឹមត្រូវនោះទេ។ តាំងចិត្តមិនដោះស្រាយបញ្ហាដោយការសម្លាប់ទារកក្នុងផ្ទៃ ដែលមានន័យដូចគ្នានឹងការសម្លាប់ទារកអាយុពីរឆ្នាំដើម្បីដោះស្រាយវិបត្តិផ្ទាល់ខ្លួន ។

**២)-សូមកុំមើលរំលងចំពោះការរម្លូតកូន**

ការនេះ ជាច្បាប់ទីពីរដែលត្រូវអនុវត្តតាម «ចូរស្រឡាញ់អ្នកដទៃឲ្យបានដូចស្រឡាញ់ខ្លួនឯង» (លេវីវិន័យ ១៩.៨)។ ការធ្វើមិនដឹងមិនឮ ជាទម្រង់មួយនៃការយល់ព្រមតាម។ បើលោកអ្នកមិនអាចធ្វើមិនដឹងមិនឮចំពោះការសម្លាប់កុមារអាយុពីរឆ្នាំ លោកអ្នកក៏ត្រូវធ្វើដូចគ្នាចំពោះការរម្លូតកូនដែរ (ចោទិយកថា ២១.៧)។ នេះហើយជាសកម្មភាពនៃការសង្គ្រោះ។

កុំមើលរំលងចំណុចដ៏សំខាន់នេះ ព្រះជាម្ចាស់ត្រាស់ហៅយើងមកឲ្យមានសកម្មភាព ធ្វើអន្តរាគមន៍ សង្គ្រោះជនស្លូតត្រង់។ យើងត្រូវក្លាហាន យើងត្រូវហ៊ាននិយាយ ហើយក៏ត្រូវមានសកម្មភាពដើម្បីសង្គ្រោះជីវិតផង។ «[១១] ចូរជួយសង្គ្រោះអស់អ្នកដែលគេកាត់ទោសប្រហារជីវិត ហើយខំប្រឹងរំដោះអស់អ្នកដែលគេនាំទៅសម្លាប់។ [១២] បើអ្នកពោលថា «ខ្ញុំមិនបានដឹងទេ!» តោងដឹងថា ព្រះជាម្ចាស់ដែលស្គាល់ចិត្តមនុស្ស ទ្រង់ជ្រាបទាំងអស់។ ព្រះអង្គពិនិត្យមើលអ្នក ទ្រង់ឈ្វេងយល់ចិត្តអ្នក ហើយព្រះអង្គតបស្នងដល់ម្នាក់ៗ តាមអំពើដែលខ្លួនប្រព្រឹត្ត» (សុភាសិត ២៤.១១-១២ បរិបទ ឃាតកម្ម ការសម្លាប់ជីវិតជនគ្មានកំហុស)។

**ក-យើងមិនអាចសម្តែងធ្វើជាមិនដឹងមិនឮ និងមិនធ្វើអ្វីសោះនោះទេ។** ព្រះជាម្ចាស់ជ្រាបពីជម្រៅចិត្តរបស់យើង ហើយព្រះអង្គនឹងវិនិច្ឆ័យយើងតាមរយៈអ្វីដែលយើងធ្វើ ឬអ្វីដែលយើងមិនធ្វើ។ ទំនួលខុសត្រូវរបស់យើងគឺត្រូវបើកមាត់និយាយ។ យើងឈ្នះភាពភ័យខ្លាចដោយក្លាហានខាងសីលធម៌ ក្រោកឈរដោយដឹងជាក់ថា ព្រះជាម្ចាស់ទតមើលការឆ្លើយតបរបស់យើងចំពោះការត្រាស់ហៅរបស់ព្រះអង្គឲ្យយើងមានសកម្មភាព។

**ខ-របៀបដែលយើងមានប្រតិកម្មចំពោះការសម្លាប់ជនគ្មានកំហុស** អ្វីដែលយើងធ្វើ គឺសម្តែងអំពីវត្តមាន (អវត្តមាន)នៃជំនឿលើព្រះជាម្ចាស់ក្នុងជីវិតរបស់យើង។

- ទំនុកតម្កើង ៨២.៣-៤ [៣] ចូររកយុត្តិធម៌ឲ្យមនុស្សទន់ខ្សោយ និងក្មេងកំព្រា ចូរកាត់ក្ដីឲ្យមនុស្សកំសត់ទុគ៌ត និងមនុស្សតោកយ៉ាក។ [៤] ចូររំដោះមនុស្សទន់ខ្សោយ និងមនុស្សក្រីក្រ ចូរយកពួកគេចេញឲ្យផុតពីកណ្ដាប់ដៃរបស់មនុស្សអាក្រក់។
- សុភាសិត ៣១.៨-៩ «[៨] ចូរនិយាយជំនួសអ្នកដែលមិនអាចនិយាយបាន ហើយរកយុត្តិធម៌ឲ្យអស់អ្នកដែលគ្មាននរណាការពារ។ [៩] ចូរនិយាយការពារ និងរកយុត្តិធម៌ឲ្យអ្នកក្រីក្រ និងជនទុគ៌ត»។

យើងធ្វើតាមច្បាប់សីលធម៌សង្ខេបរបស់ព្រះជាម្ចាស់ផ្ទាល់ (ក្រិត្យវិន័យទាំងមូល និង ពួកព្យាការី)។
- ម៉ាថាយ៧.១២ «ដូច្នេះ បើអ្នករាល់គ្នាចង់ឲ្យអ្នកដទៃប្រព្រឹត្តចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ។ គម្ពីរវិន័យ និងគម្ពីរព្យាការីមានចែងទុកមកដូច្នេះឯង»។
- កាឡាទី ៥.១៤ ដ្បិតក្រឹត្យវិន័យទាំងមូលសរុបមកត្រឹមតែឃ្លាមួយនេះថា *«អ្នកត្រូវស្រឡាញ់បងប្អូនទៀតៗឲ្យបានដូចស្រឡាញ់ខ្លួនឯងដែរ»*។

ព្រះជាម្ចាស់ *បង្ហាញ* របៀបជួយសង្គ្រោះ ដែលជាគំរូនៃកិច្ចការអន្តរាគមន៍ លូកា ១០.២៥-៣៧។ រឿងសាសន៍សាម៉ារីចិត្តសប្បុរស បង្ហាញយើងពី *របៀប* ជួយសង្គ្រោះ (លូកា ១០.២៥-៣៧)។ រឿងនេះដើរតួជាគំរូក្នុងការតម្រង់ទិសដែលមានប្រយោជន៍ និងជាលក្ខណៈបុគ្គល ដែលជាតម្លៃផ្ទាល់ខ្លួនទាំងពេលវេលា និងប្រាក់កាស ក្នុងការសង្គ្រោះជីវិតជាច្រើន និងលើកតម្កើងសិរីរុងរឿងដល់ព្រះជាម្ចាស់ ដែលសម្ដែងពីសកម្មភាពមិនអាត្មានិយមស្ដែងចេញពីនចិត្តក្តួលអាណិត។

រឿងសាសន៍សាម៉ារីចិត្តសប្បុរសសម្ដែងឲ្យឃើញ ៖
- អ្នកជិតខាងរបស់យើងគឺ អស់អ្នកដែលត្រូវការជួយសង្គ្រោះ ជាពិសេសគឺជួយឲយរួចពីស្លាប់។
- របៀបដែលយើងត្រូវជួយសង្គ្រោះ ដោយចិត្តអាណិតអាសូរ ចិត្តសន្ដោសមេត្តា លក្ខណៈផ្ទាល់ខ្លួនដែលអាចយកជាការបាន ទោះត្រូវចំណាយពេលវេលា និង ប្រាក់កាស។
- តើអ្នកណាជាអ្នកជិតខាងដ៏ល្អ (គឺអ្នកដែលមានចិត្តមេត្តាដល់គាត់) អស់អ្នកដែលមិនមើលនឹងភ្នែកជួយ និង សង្គ្រោះផង។

## ឧទាហរណ៍អំពីការស្ដាប់បង្គាប់ការត្រាស់ហៅរបស់ព្រះជាម្ចាស់ឲ្យជួយសង្គ្រោះជនស្លូតត្រង់

តើត្រូវជួយសង្គ្រោះជនស្លូតត្រង់ដោយរបៀបណា ក្នុងពេលដែលពួកកំពុងក្លាយជាគោលដៅនៃការសម្លាប់? យើងនឹងពិនិត្យមើលគំរូក្នុងព្រះគម្ពីរ និងជាប្រវត្តិសាស្រ្ត។

### ១-គំរូ និង មធ្យោបាយក្នុងព្រះគម្ពីរ

**ក-លោករ៉ូបេន** បានជួយសង្គ្រោះលោកយ៉ូសែបពីការសម្លាប់របស់បងៗរបស់ខ្លួន។ លោកបានបើកមាត់និយាយ និងប្រើការបញ្ចុះបញ្ចូលប្រកបដោយក្រមសីលធម៌ ទាំងទទូច និង ផ្ដល់មធ្យោបាយដ៏ប្រសើរផ្សេងទៀតដែលពង្វាងពីការប៉ុនប៉ងធ្វើឃាត។



គម្ពីរលោកុប្បត្តិ ៣៧.២១-២២ ចែងថា ៖«
[២១] ពេលលោករូបេនឮដូច្នោះ គាត់ចង់ជួយយ៉ូសែបឲ្យរួចពីកណ្ដាប់ដៃពួកគេ។ គាត់ពោលថា៖ «កុំប្រហារជីវិតវាធ្វើអ្វី»
។ [២២] លោករូបេនពោលថែមទៀតថា៖ «កុំបង្ហូរឈាមវាធ្វើអ្វី គឺគ្រាន់តែបោះវាទៅក្នុងអណ្ដូងនៅវាលរហោស្ថាននេះបានហើយ

មិនបាច់សម្លាប់វាទេ»។ គាត់ពោលដូច្នេះ មកពីចង់រំដោះយ៉ូសែបឲ្យរួចពីកណ្ដាប់ដៃបងៗ ហើយនាំយកទៅជូនឪពុកវិញ»។

**ខ-ឆ្មបនៅស្រុកអេស៊ីបសុខចិត្តគោរពកោតខ្លាចព្រះជាម្ចាស់** ដោយល្មើសបទបញ្ជាស្ដេចដ៏អាក្រក់នៃស្រុកអេស៊ីបដែលបញ្ជាឲ្យសម្លាប់ទារកប្រុសៗដែលទើបកើតមក ឆ្មបទាំងនោះបានសង្គ្រោះទារកភេទប្រុសដែលទើបនឹងកើតឲ្យពីការសម្លាប់នៅជំនាន់របស់លោកម៉ូសេ។ កាលស្ដេចបានដឹងក៏ហៅឆ្មបទាំងនោះមកសួរពីមូលហេតុដែលឆ្មបទាំងនោះបានជួយសង្គ្រោះទារកប្រុសឲ្យមានជីវិត? ពួកគេឆ្លើយដោយឈ្លាសវៃ ហើយបន្តជួយទារកទាំងនោះដោយក្លាហាន។ គម្ពីរនិក្ខមនំ ១.១៧ បញ្ជាក់ថា ៖«ប៉ុន្តែ ឆ្មបទាំងពីរនាក់នោះគោរពកោតខ្លាចព្រះជាម្ចាស់ គាត់មិនបានធ្វើតាមបញ្ជារបស់ស្ដេចស្រុកអេស៊ីបទេ គឺគាត់ទុកឲ្យកូនប្រុសៗនៅរស់ដែរ»។

**គ-ម្ដាយរបស់លោកម៉ូសេ** បានជួយសង្គ្រោះលោក ដោយលាក់ទារកម៉ូសយ៉ាងមានសុវត្ថិភាពនៅក្នុងផ្ទះ (និក្ខមនំ ២.១-១០)។ លុះក្រោយមកនាងបានថ្វាយលោកឲ្យទៅជាបុត្រចិញ្ចឹម ដើម្បីផ្ដល់ឲ្យលោកមានកន្លែងសុវត្ថិភាពក្នុងចម្រើនធំធាត់ និងបំពេញផែនការរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់លោក។ គម្ពីរកិច្ចការ ៧.១៩-២១ ចែងថា ៖«[១៩] ស្ដេចថ្មីនោះបានប្រើល្បិចអាក្រក់មកលើពូជសាសន៍យើង គឺទ្រង់បានធ្វើបាបបុព្វបុរសរបស់យើង រហូតដល់បង្ខំពួកគាត់ឲ្យយកទារកតូចៗរបស់ខ្លួនទៅបំបរបង់ចោល ដើម្បីកុំឲ្យមានជីវិតរស់តទៅមុខទៀត។ [២០] លោកម៉ូសេបានកើតនៅជំនាន់នោះ ហើយលោកជាទារកមួយដ៏ស្អាត ជាទីគាប់ព្រះហឫទ័យព្រះជាម្ចាស់។ ឪពុកម្ដាយបានចិញ្ចឹមលោកនៅក្នុងផ្ទះអស់រយៈពេលបីខែ។ [២១] កាលគេបំបរបង់លោកចោល បុត្រីរបស់ស្ដេចផារ៉ោនបានរើសលោកយកមកចិញ្ចឹមបីបាច់ថែរក្សា ធ្វើជាកូន»។

**ឃ-លោកអូបាឌា** បានសង្គ្រោះព្យាការី១០០នាក់ពីការតាមសម្លាប់របស់ព្រះនាងយេសេបិល ដោយផ្ដល់ទីកន្លែងស្នាក់នៅដ៏មានសុវត្ថិភាព។ គម្ពីរ ១ពង្សាវតាក្សត្រ១៨.៤ ៖«នៅគ្រាដែលម្ចាស់ក្សត្រីយេសិបិលសម្លាប់ពួកព្យាការី*របស់**ព្រះអម្ចាស់** លោកអូបាឌានាំព្យាការីមួយរយនាក់ទៅពួននៅក្នុងរអាងភ្នំ គាត់ចែកពួកគេជាពីរក្រុម ក្នុងមួយក្រុមមានហាសិបនាក់ ហើយគាត់បានផ្គត់ផ្គង់ស្បៀងអាហារ និងទឹកផង»។

**ង-នាងរ៉ាហាប** បានសង្គ្រោះអ្នកសើបការណ៍ ដោយប្រើល្បិចកលដ៏ក្លាហាន លាក់បំពួនអ្នកស៊ើបការណ៍ ព្រមទាំងកុហកដើម្បីសង្គ្រោះពួកគេផង។ គ្រួសាររបស់នាងទាំងមូលក៏បានរួចជីវិត (យ៉ូស្វេ ២, ៦.២២-២៥) សកម្មភាពរបស់នាងត្រូវ បានលើកសរសើរ (យ៉ាកុប ២.២៥, ហេប្រឺ ១១.៣១)។

**ច-មនុស្សមួយហ្វូងធំ** ក្រោកឈរឡើងជាសម្លេងតែមួយដើម្បីសង្គ្រោះសម្ដេចយ៉ូណាថាន។ គម្ពីរ ១សាំយ៉ូអែល ១៤.៤៥ ចែងថា ៖«ពួកទាហានទូលព្រះបាទសូលថា៖ «សម្ដេចយ៉ូណាថានមិនត្រូវសុគតឡើយ! ដ្បិតសម្ដេចទេតើដែលដណ្ដើមបានជ័យជំនះដ៏ធំធេងនេះឲ្យប្រជាជាតិអ៊ីស្រាអែល។ យើងខ្ញុំសូមស្បថ ក្នុងនាម**ព្រះអម្ចាស់**ដែលមានព្រះជន្មគង់នៅថា យើងខ្ញុំមិនព្រមឲ្យសក់មួយសរសៃជ្រុះពីសិរសារបស់សម្ដេចឡើយ ដ្បិតព្រះជាម្ចាស់បានជួយសម្ដេចឲ្យប្រព្រឹត្តដូច្នេះ នៅថ្ងៃនេះ»។ ពួកទាហានក៏បានសង្គ្រោះសម្ដេចយ៉ូណាថានឲ្យរួចពីស្លាប់»។

**ឆ-ព្រះនាងអេសធើរ** បានសង្គ្រោះប្រជារាស្ត្ររបស់ព្រះនាងពីការប្រល័យពូជសាសន៍ស្របច្បាប់ តាមរយៈកិច្ចទាមទារឲ្យកែប្រែច្បាប់។ ព្រះនាងប្រថុយព្រះជន្ម និយាយជំនួសអ្នកដែលត្រូវបានបម្រុងទុកសម្រាប់ ស្លាប់។ គម្ពីរអេសធើរ៣.៩-១៣ និង ៤.១៤-១៦ ចែងថា ៖«...ខ្ញុំនឹងទៅគាល់ស្ដេចទោះបីខុសច្បាប់ក៏ដោយ បើខ្ញុំត្រូវវិនាស នោះឲ្យវិនាសទៅចុះ»។

**ជ-ព្រះយេស៊ូ** បង្រៀនយើងឲ្យរកគ្រប់មធ្យោបាយ និងមានសកម្មភាពយ៉ាងរហ័ស ព្រមទាំងប្រើប្រាស់អ្វីដែលអាចប្រើបាន រួមទាំងពេលវេលា និង ប្រាក់កាសរបស់យើងផង ដើម្បី*ជួយសង្គ្រោះ* ជីវិតមនុស្សលោក តាមគំរូនៃការសង្គ្រោះជីវិតរបស់សាសន៍សាម៉ារីចិត្តសប្បុរស (លូកា ១០.២៥-៣៧)។

## ២-មធ្យោបាយ និង គំរូជាប្រវត្តិសាស្ត្រ

**ក-សតវត្សរ៍ទី១** ។ ក្រុមជំនុំដើម។ ការពន្លូតកូន និង ការសម្លាប់ទារកក្នុងពិភពអាណាចក្ររ៉ូមនាសតវត្សរ៍ទី១គឺជារឿងធម្មតា។ ជាញឹកញាប់ ឪពុកម្ដាយ តែងយកកូនតូចរបស់ខ្លួនទៅបំបរបង់ចោលនៅក្នុងព្រៃឬតាមចិញ្ចើមផ្លូវ ឲ្យស្លាប់ដោយកត្តាផ្សេងៗ ឬស្លាប់ដោយសត្វព្រៃហែកស៊ី។ ទារកខ្លះទៀតត្រូវបានចិញ្ចឹមឲ្យធ្វើជាទាសករ និងជាស្ត្រីពេស្យា។ ក្រុមជំនុំដើម បានបង្រៀនអ្នកជឿ *«កុំសម្លាប់ទារកដោយការរម្លូត ឬសម្លាប់ទារកដែលទើបកើតមកឲ្យសោះ»* ឯកសារមួយហៅថា «ឌីដអាឃី (Didache) (ឯកសារសេចក្ដីបង្រៀនគោលរបស់ក្រុមសាវ័កទាំង១២)»។ គេក៏បានបង្រៀនថា *«មានវិធីសាស្ត្រពីរយ៉ាង គឺ វិធីសាស្ត្រនៃជីវិត និង វិធីសាស្ត្រនៃសេចក្ដីស្លាប់ ហើយវាមានភាពខុសគ្នាយ៉ាងខ្លាំងរវាងវិធីសាស្ត្រទាំងពីរនេះ»* ។ វិធីសាស្ត្រនៃសេចក្ដីស្លាប់រួមមាន ៖ ការសម្លាប់កុមារ និងបំផ្លាញស្នាព្រហស្តដែលមានលក្ខណៈដូចព្រះជាម្ចាស់របស់ព្រះជាម្ចាស់។ ពួកគេបានជួយសង្គ្រោះ និងចិញ្ចឹមទារកជាច្រើន ព្រមទាំងជួយស្ត្រីមានផ្ទៃពោះឲ្យរក្សាភគ៌ក្នុងផ្ទៃរបស់ខ្លួនផង។



**ខ-សតវត្សរ៍ទី២** ទេវវិទូនាមលោកធឺធូលៀន (គស១៦០-២២០) ជាអ្នកដឹកនាំផ្នែកអភិរក្សជំនឿបានការពារចរិយាសាស្ត្រជីវិត។ លោកបានលើកក្នុងសំណេលម្អិតស្ដីអំពីវិធីសាស្ត្រដ៏រន្ធត់ក្នុងការរម្លូតកូននៅជំនាន់របស់លោក។ លោកមានប្រសាសន៍អំពីគ្រិស្តបរិស័ទថា ៖«ក្នុងករណីរបស់យើងនេះ ការសម្លាប់ត្រូវបានហាមឃាត់ ។ ដូច្នេះយើងមិនត្រូវបំផ្លាញសូម្បីគភ៌ក្នុងផ្ទៃ...»។

**គ-សតវត្សរ៍ទី៤** លោកអគូស្ទីន (គស ៣៥៤-៤៣០) បានលាតត្រដាងដោយបន្ទោសដល់ការប្រាសចាកសីលធម៌ដែលបុរសបានធ្វើក្នុងពេលរម្លូតកូន ដោយលោកមានប្រសាសន៍ថា ៖«គេជម្រុញលួងលោមឲ្យស្ត្រីប្រើប្រាស់ថ្នាំពុលដើម្បីកុំឲ្យមានកូនកើត ឬបើវិធីនេះមិនជោគជ័យគឺគេសម្លាប់ដោយរម្លូតទារកតែម្ដង»។

**ឃ-សតវត្សរ៍ទី៦** ព្រះចៅ ចាស្ទីនៀនទី១ (គស៤៨៣-៥៦៥) ជាស្ដេចចក្រភពរូម និង ជាគ្រិស្តបរិស័ទផងនោះបានបង្រៀនថា ៖ «អ្នកណារកបានកូនតូច ដូចជាបានផ្ដល់ឲ្យគ្រិស្តបរិស័ទមានការថែទាំ និង ការអាណិតអាសូរ។ គេអាចនឹងយកកូនតូចនោះមកចិញ្ចឹម ដូចជាយើងបានទទួលជាកូនចិញ្ចឹមក្នុងព្រះរាជនៃព្រះគុណដែរ»។

**ង-សតវត្សរ៍ទី១៣** ទស្សនៈវិទូនាមលោក ថូម៉ាស អាគ្វីណាស (គស ១២២៥-១២៧៤) បានបដិសេធការរម្លូតកូនជាថា រឿងមិនត្រឹមត្រូវក្នុងគ្រប់ដំណាក់កាល ដោយចាត់ទុកថា «ជាអំពើបាបប្រឆាំងធម្មជាតិដែលបដិសេធព្រះអំណោយទាននៃជីវិតរបស់ព្រះជាម្ចាស់»។

**ច-សតវត្សន៍ទី១៦ (គ្រាបដិរូបកម្ម)** លោកចនកាល់វីនបានប្រកាសថា ៖ «ទោះបីជាមានការប្រកាសសេចក្ដីពិត

របស់ព្រះជាម្ចាស់ទាស់នឹងការកុហករបស់សាតាំង ឬរួមចំណែកក្នុងការការពារមនុស្សល្អ និងជនស្លូតត្រង់គ្នី ... យើងត្រូវឆ្លងកាត់ការបំពាន និងការស្អប់ខ្ពើមដែលពេញដោយភាពអស្ចារ្យ...ជាជីវិត ជោគវាសនា ឬកិត្តិយសរបស់យើង»។

**ឆ-សតវត្សន៍ទី១៨ ដល់សតវត្សរ៍ទី២០** លោកវីល្លៀម គែរី (គស១៧៦១-១៨៣៤) ជាបេសកជនទៅកាន់ប្រទេសឥណ្ឌា បានបញ្ឈប់ការបោះទារកទៅក្នុងទន្លេឲ្យសត្វក្រពើស៊ី និងបានប្រឆាំងឲ្យបញ្ឈប់ពិធីសាសនាមួយហៅថា «សាទី» ដែលដុតប្រពន្ធទាំងរស់ជាមួយនឹងការបូជាសពរបស់ប្តីខ្លួន។ អ្នកស្រីមារី-ស្លេស័រ ជាបេសកជនទៅកាន់អាហ្វ្រិក បានសង្គ្រោះកូនភ្លោះជាច្រើននាក់ពីកាសម្លាប់បូជាយញ្ញ និងបញ្ឈប់ការប្រព្រឹត្តិមន្តអាគមន៍។ អ្នកម្តាយថេរេសា (គស១៩១០-១៩៩៧) ជាបេសកជនទៅកាន់ប្រទេសឥណ្ឌា បានរៀបចំផ្ទះសម្រាប់កុមារ និងបានសង្គ្រោះកុមារជាច្រើន ហើយបានទទួលពួកមកចិញ្ចឹមជាគ្រួសារ។ អ្នកម្តាយមានប្រសាសន៍ថា ៖«សូមមេត្តាកុំសម្លាប់កុមារ...សូមយកពួកគេមកឲ្យខ្ញុំ។ ខ្ញុំស្ម័គ្រចិត្តទទួលយក ទារកណាដែលម្តាយចង់រម្លូតចោល...»។

គ្រិស្តបរិស័ទបានបង្កើតមណ្ឌលកុមារកំព្រា មន្ទីរពេទ្យ បានទទួលកុមារតូចៗជាកូនចិញ្ចឹម និងជួយទាសករចេញពីសហរដ្ឋអាមេរិក បានជួយលាក់បាំងបេសកជនជាច្រើន ក្នុងអំឡុងពេលនៃការបះបោររបស់អ្នកគុណនិយមនៅប្រទេសចិន ព្រមទាំងសង្គ្រោះជនជាតិយូដាពីការតាមសម្លាប់របស់ពួកណាស៊ីក្នុងសង្គ្រាមលោកលើកទី២។ អ្នកដឹកនាំក្រុមជំនុំបង្រៀនក្រុមជំនុំរបស់ខ្លួន ឲ្យនិយាយប្រឆាំងនឹងការរម្លូតកូន ព្រមទាំងមានសកម្មភាពជួយសង្គ្រោះស្ត្រី និងទារកពីការរម្លូតចេញ និងការសម្លាប់កូនក្មេងផង។ បេសកជនប្រកាសដំណឹងល្អ ស្របពេលនោះក៏ជួយសង្គ្រោះអស់អ្នកដែលងាយរងគ្រោះដល់ជីវិត ហើយក៏បង្រៀនមនុស្សឲ្យលះបង់ការអាក្រក់ចោលចេញ។

## ៣-មធ្យោបាយ និង គំរូសម័យទំនើប

**ក-អន្តរាគមន៍ចំពោះវិបត្តិនៃការមានផ្ទៃពោះ** -ការជួយសង្គ្រោះស្ត្រី និង ទារកពីការរម្លូតកូន។
គ្រិស្តបរិស័ទបច្ចុប្បន្នកំពុងជួយសង្គ្រោះជីវិតទារកស្លូតត្រង់ជាច្រើនដូចនៅជំនាន់លោកម៉ូសេ និង ជំនាន់ក្រុមជំនុំដើមដែរ តាមរយៈការជួយម្តាយ និងគូស្វាម៉ីភរិយាដោះស្រាយវិបត្តិនៃការមានផ្ទៃពោះនៅក្នុងសហគមន៍របស់គេ។

*ការជួយលក្ខណៈផ្ទាល់ខ្លួន* មនុស្សមានសកម្មភាពតាមរបៀបសាសន៍សាមារីចិត្តសប្បុរស ពេលគេជួបនរណាម្នាក់ដែលមានវិបត្តិនៃការមានផ្ទៃពោះ គឺគេមានសកម្មភាពឆាប់រហ័ស និងគ្រប់មធ្យោបាយផ្ទាល់ខ្លួនទាំងអស់ ដើម្បីជួយស្ត្រី និងសង្គ្រោះទារក តាមរយៈការផ្តល់ជំនួយដល់បុគ្គលផ្ទាល់។ *ការជួយលក្ខណៈជាក្រុម* គ្រិស្តបរិស័ទតាមតំបន់ និងក្រុមជំនុំចាត់ចែងឲ្យមានព័ន្ធកិច្ចជួយស្ត្រីមានផ្ទៃពោះដែលសមស្របសម្រាប់តាមលក្ខណៈ ភូមិសាស្រ្ត និងសេចក្តីត្រូវការរបស់គេ ហើយជារៀងរាល់ឆ្នាំបានកំពុងជួយសង្គ្រោះជីវិតទារកជាច្រើននៅជុំវិញពិភពលោក។

ធម្មតា *ក្រុមជួយសង្គ្រោះស្ត្រីមានផ្ទៃពោះ* មានសេវាកម្មដូចជា ការប្រឹក្សាដោះស្រាយវិបត្តិ ការគាំទ្រផ្នែកផ្លូវចិត្ត និងផ្តល់ព័ត៌មានផ្នែកវិជ្ជាសាស្រ្ត (ព័ត៌មាន រូបភាព វីដេអូរ) ដើម្បីជួយស្ត្រី ឬដៃគូឲ្យធ្វើការសម្រេចចិត្តប្រឆាំងនឹងការរម្លូតកូន។ ពួកគេអាចជួយស្វែងរកការថែទាំផ្នែកវិជ្ជសាស្រ្ត និងទទួលបានការធ្វើអាល់ត្រាសោន ឬការឆ្លុះអេកូរសម្រាប់ស្ត្រី។ ក៏អាចនឹងជួយបុរសវ័យក្មេងឲ្យក្លាយជាឪពុកដែលមានការទទួលខុសត្រូវ និងជួយម្តាយថ្មោងថ្មីឲ្យមានជំនាញក្នុងការចិញ្ចឹមកូន ឬប្រហែលជួយផ្តល់កន្លែងសម្រាប់ទទួលទារកជាកូនចិញ្ចឹមផង។ ការផ្តល់ជំនួយនេះត្រូវកើតមានតាំងពីមុនពេល អំឡុងពេល និងក្រោយការសម្រាល ព្រមទាំងជួយរក្សាមិត្តភាពយូរអង្វែងផង។

ក្រុមនេះ ក៏អាចនឹងបើក *មជ្ឈមណ្ឌលជួយស្ត្រីមានផ្ទៃពោះ* ជាកន្លែងដែលគេអាចជួប និងផ្តល់ប្រឹក្សាដល់ស្ត្រីដែលមានវិបត្តិ។ ក៏អាចជាកិច្ចការធម្មតានៅក្នុងគ្លីនិកមួយ ក្នុងបន្ទប់នៃមន្ទីរពេទ្យមួយ ឬនៅកន្លែងផ្ទះជួលតាម ជញ្ជើមផ្លូវណាមួយ នៅពេលដែលដឹងដំណឹងអំពីការរម្លូតកូន។ គោលបំណង គឺដើម្បីជួបស្ត្រី ឬគូស្វាមីភរិយាមុនពេលគេធ្វើការសម្រេចចិត្តរម្លូតកូន ឬអស់អ្នកដែលប្រុងនឹងរម្លូតកូនដោយផ្តល់ជម្រើសផ្សេងមកជំនួសវិញ។ មជ្ឈមណ្ឌលនោះត្រូវតែងាយរកនិងមើលឃើញជាសាធារណៈ។

ក្រុមការងារក៏អាចបើក *ជម្រកសុវត្ថិភាពសម្រាប់ម្តាយ និងទារក* ឬ *មណ្ឌលសុវត្ថិភាពកុមារ* សម្រាប់ស្ត្រី និងកុមារអាចស្នាក់នៅ។ ស្ត្រីខ្លះប្រឈមនឹងការបោះបង់ចោល សម្ពាធចំពោះការរម្លូត ឬអំពើហិង្សារ ហើយត្រូវការកន្លែងសុវត្ថិភាពដើម្បីស្នាក់នៅត្រៀមសម្រាលកូន។ ទីជម្រកអាចជួយឲ្យស្នាក់នៅមុនពេល អំឡុងពេល និង ក្រោយការសម្រាល។ គោលបំណង គឺដើម្បីគាំទ្រអស់អ្នកដែលត្រូវការជំនួយ ជាពិសេសផ្តល់ជម្រកសុវត្ថិភាពសម្រាប់ស្នាក់នៅ។ សេវាកម្មនេះ នឹងត្រូវបានផ្សព្វផ្សាយ ប៉ុន្តែមជ្ឈមណ្ឌលត្រូវផ្តល់ដំណឹងជាលក្ខណៈឯកជនដើម្បីសុវត្ថិភាព។

ពេលជួយស្ត្រីម្នាក់ដែលកំពុងពិចារណារម្លូតកូន *(ប្រឈមនឹងវិបត្តិនៃការមានផ្ទៃពោះ)* ខាងក្រោមនេះជាអ្វីដែលលោកអ្នកត្រូវនិយាយ និងធ្វើ ៖

- បង្ហាញការយល់ចិត្ត។ សូមនិយាយដូច្នេះថា ៖«ខ្ញុំសោកស្តាយណាស់ដែលបានឃើញអ្នកស្រីស្ថិតក្នុងស្ថានការណ៍ដ៏លំបាកនេះ»។
- ស្តាប់ និងរៀន។ សូមនិយាយថា ៖ «សូមពន្យល់ខ្ញុំពីមូលហេតុដែលទារកក្នុងផ្ទៃនាំផលលំបាកដល់អ្នកស្រី»។
- បញ្ជាក់អះអាង ។ សូមសួរសំណរនេះថា ៖ «តើអ្នកស្រីបានដឹងអ្វីខ្លះទាក់ទងនឹងទារកក្នុងផ្ទៃរបស់អ្នកស្រី? ការរម្លូត? ជម្រើស?»។
- សូមធ្វើជាសាសន៍សាម៉ារីចិត្តសប្បុរសម្នាក់។ សូមនិយាយថា ៖ «ខ្ញុំនឹងជួយអ្នកស្រីក្នុងការមានកូននេះ។ យើងនឹងដោះស្រាយរឿងនេះជាមួយគ្នា។»

ការបង្កើតក្រុមជួយស្ត្រីមានផ្ទៃពោះ ដើម្បីឈោងចាប់ស្ត្រីក្នុងសហគមន៍របស់លោកអ្នក។ ដោយចាប់ផ្តើមតាមរយៈ ៖

- ប្រមូលគ្រិស្តបរិស័ទចាស់ទុំខាងជំនឿជុំគ្នា យល់ព្រមធ្វើការ និងអធិស្ឋានជាមួយគ្នា។ សួរយោបល់ពីគ្រូគង្វាលរបស់លោកអ្នក។
- ហ្វឹកហ្វឺនក្រុមរបស់អ្នក ដោយបង្រៀនពួកគេពីរបៀបផ្តល់ប្រឹក្សាដល់ស្ត្រី និងស្វាមីភរិយាដែលមានវិបត្តិនៃការ មានផ្ទៃពោះ។
- រៀនអំពីការរម្លូតកូននៅទីតាំងរបស់លោកអ្នក។ កន្លែងណា? នរណាខ្លះ? ប៉ុន្មាននាក់? ហេតុអ្វី?
- ត្រៀមខ្លួនដើម្បីនឹងជួយស្ត្រីណាដែលត្រូវការជំនួយរបស់លោកអ្នក ចែករំលែកតាមអនទ្បាញ ក្រុមឆាតសួរសុខទុក្ខ/និយាយជាមួយមនុស្ស...។
- រកឲ្យឃើញស្ត្រីដែលមានផ្ទៃពោះដទៃទៀត ជួយផ្តល់ធនធានក្នុងសហគមន៍។ តើនរណាអាចជួយគាត់បាន? គ្រូពេទ្យនៅឯណា?

**ខ-បង្ហាញការមិនគាំទ្រចំពោះការរម្លូតកូន** ចែករំលែកជាមួយសហគមន៍ក្រៅក្រុមជំនុំ និង មិត្តភក្តិរបស់អ្នក ៖ យើងអាចផ្លាស់ប្តូររបៀបគិតរបស់សហគមន៍ក្រៅក្រុមជំនុំអំពីការរម្លូតកូន ដោយបង្ហាញពីភាពចាំបាច់ដើម្បី *ការពារជីវិត*ទារកក្នុងផ្ទៃ តាមរបៀបដែលវប្បធម៌លោកិយអាចទទួលយកបាន។ មិនចាំបាច់លើកយកសេចក្តីយោងពីក្នុងព្រះគម្ពីរ យើងអាចចែកចាយអំពី ៖

ទី១-សង្ខេបករណី

- ជារឿងមិនត្រឹមត្រូវទេដែលមានចេតនាសម្លាប់ជីវិតស្លូតត្រង់ម្នាក់នោះ។
- ទារកក្នុងផ្ទៃជាមនុស្សពេញលេញ។ ការរម្លូតកូនជាការសម្លាប់ជីវិតជនស្លូតត្រង់ដោយចេតនា។
- ការរម្លូតកូនជារឿងមិនត្រឹមត្រូវទេ។

ទី២-ប្រើប្រាស់វិទ្យាសាស្ត្រ (សូមមើលសំណួរទី១) ដើម្បីឆ្លើយនឹងសំណួរថា ៖ តើទារកក្នុងផ្ទៃជាអ្វី? តើវាជាមនុស្សមែនទេ?

ទី៣-ប្រើប្រាស់ហេតុផលសីលធម៌ដោយបង្ហាញថា មនុស្សលោកគ្រប់រូបមានសិទ្ធិទទួលការការពារដូចគ្នា។ សួរសំណួរថា «តើជារឿងត្រឹមត្រូវឬទេ បើសម្លាប់ទារកអាយុពីរខួប?» ។ មនុស្សជាច្រើនប្រាកដជាឆ្លើយថា «មិនត្រឹមត្រូវទេ»។ មិនថាគេមានហេតុផលយ៉ាងណាទេ ក៏គេមិនសម្លាប់ទារកអាយុពីរឆ្នាំដែរ។ ប៉ុន្តែមនុស្សព្យាយាមបញ្ជាក់ពីភាពត្រឹមត្រូវនៃការរម្លូតកូនដោយឲ្យយោបល់ថា *ទារកក្នុងផ្ទៃមិនមែនជាមនុស្សគ្រប់លក្ខណៈទេ គឺខុសគ្នានឹងទារកអាយុពីរឆ្នាំ។* ជាញឹកញាប់ គេតែងចង្អុលទៅរកភាពខុសគ្នាបួនចំណុច ដែលគ្មានចំណុចណាមួយអាចធ្វើឲ្យការរម្លូតកូនជារឿងត្រឹមត្រូវសោះ។ ខាងក្រោមនេះការរែកញែក និង របៀបដែលគេឆ្លើយតប ៖

-**ទារកក្នុងផ្ទៃនៅតូចទេ** ។ ជាការពិត។ អំព្រីយ៉ុងជីវិតគឺតូចជាងក្មេងអាយុពីរឆ្នាំមែន ហើយក្មេងអាយុពីរឆ្នាំក៏តូចជាងក្មេងជំទង់ដែរ។ គោលការណ៍នៃសិទ្ធិស្មើគ្នា មិនពាក់ព័ន្ធនឹងមាឌតូចធំនោះទេ។ សិទ្ធិមិនមែនជាអ្វីដែលធ្វើមាឌធំឬតូចនោះទេ។ ជាទូទៅ បុរសមានមាឌធំជាងស្ត្រី។ តើការនេះមានន័យថា បុរសនោះមានសិទ្ធច្រើនជាងស្ត្រីមែនទេ?

-**ទារកនោះនៅក្នុងផ្ទៃនៅឡើយ** ។ ជាការពិតមែន។ ប៉ុន្តែទីកន្លែងក៏មិនអាចកំណត់ភាពពិតជាលោកអ្នកដែរ។ ទីតាំង មិនទាក់ទងនឹងទស្សនៈសិទ្ធិស្មើរគ្នាទេ។ អ្នកនៅក្នុងផ្ទះមិនមែនមានសិទ្ធិធំជាងអ្នកនៅខាងក្រៅផ្ទះនោះទេ។ គ្មាន អ្វីអាចផ្លាស់ប្តូរភាពជាមនុស្សរបស់កុមារទោះបីឆ្លងកាត់ការបង្ករកំណើត រហូតដល់ពេលបម្រុងនឹងកើតក្តី ក៏ការចាប់កំណើតមិនអាចផ្លាស់ប្តូរភាពជាមនុស្សរវាងទារកមុនកំណើត ពីភាពមិនមែនមនុស្សទៅជាភាពជាមនុស្សនោះទេ។

-**ទារកក្នុងផ្ទៃមិនទាន់ដឹងអីទេ** ។ ពិតមែន ។ កុមារអាយុពីរឆ្នាំមានការយល់ដឹងតិចជាងក្មេងជំទង់។ មនុស្សដែលដេកលក់ស្កប់ ឬមនុស្សដែលកំពុងស្ថិតក្នុងការវះកាត់មិនដឹងខ្លួនដូចជាមនុស្សធម្មតាឡើយ។ ប៉ុន្តែសិទ្ធិជាមនុស្សរបស់គេ មិនចម្រើនឡើង ហើយក៏មិនធ្លាក់ចុះតាមកម្រិតនៃការយល់ដឹងរបស់ខ្លួនឡើយ។ តើវាជាហេតុផលខាងសីលធម៌ឬទេ សម្រាប់មនុស្សដែលកំពុងស្ថិតក្នុងការវះកាត់ ឬមនុស្សដែលមានកម្រិតនៃការយល់ដឹងទាប តើវាមិនពាក់ព័ន្ធនឹងសិទ្ធិទេមែនទេ?

-**ទារកក្នុងផ្ទៃនៅពឹងផ្អែកទាំងស្រុងលើម្តាយ** ។ ពិតជាអញ្ចឹងមែនហើយ។ ទារកទាំងអស់ ទាំងកុមារតូចៗ ហើយសូម្បីតែក្មេងជំទង់ក៏នៅតែពឹងផ្អែកទាំងស្រុងលើអ្នកដទៃដែរ។ មនុស្សចាស់ជរា និងមនុស្សមានជំងឺក៏ត្រូវការពឹងផ្អែកលើអ្នកដទៃដែរ។ អស់អ្នកដែលពឹងផ្អែកទាំងស្រុងលើថ្នាំអាំងស៊ីលីនក៏មិនបានបង់សិទ្ធិ

រស់រានមានជីវិតរបស់គេដែរ។ ព្រះជាម្ចាស់មានព្រះបន្ទូលថា មនុស្សដែលពឹងផ្អែកលើគេ ជាមនុស្សដែលត្រូវថែរក្សា មិនមែនជាមនុស្សដែលត្រូវបំផ្លាញ ឬត្រូវសម្លាប់ចោលនោះឡើយ។ ឬមួយមនុស្សព្យាយាមបញ្ជាក់ពីភាពស្អាតស្អំនៃការរម្លូតកូន ដោយផ្អែកលើស្ថានភាពរបស់ស្ត្រី ឬស្ថានភាពគ្រួសារ ការពុះពារ និង ទុក្ខលំបាក តែគេបានសន្មត់ជាមូលដ្ឋានថា *ទារកក្នុងផ្ទៃមិនមែនជាមនុស្សពេញលក្ខណៈដូចអ្នក និង ខ្ញុំនោះទេ* តាមពិតគឺជាមនុស្សដូចគ្នា។ សូមបញ្ជាក់ម្តងទៀត ឲ្យគេកាន់តែច្បាស់ និង យល់ជាក់ដោយសួរសំណួរបន្ថែមថា បើការនោះជារឿងត្រឹមត្រូវសុចរិតមែន ដូច្នេះការម្លាប់ក្មេងអាយុពីរឆ្នាំក៏ជារឿងត្រឹមត្រូវដូចគ្នាដែរ។

-បញ្ហាលុយកាក់ *គ្រួសារយើងក្រណាស់ ។ យើងគ្មានសមត្ថភាពចិញ្ចឹមកូនទេ។* តើជារឿងត្រឹមត្រូវទេដែលសម្លាប់មនុស្សដោយព្រោះគេជាហេតុនាំឲ្យយើងបង្កើនការចំណាយ? ឧបមាថា គ្រួសារមួយបានសម្រេចចិត្តសម្លាប់កូនអាយុពីរឆ្នាំចោល ដើម្បីកាត់បន្ថយបន្ទុកចំណាយក្នុងគ្រួសារ។ តើការនេះ ជារឿងត្រឹមត្រូវឬទេ? គឺមិនត្រឹមត្រូវសោះឡើយ ឯការរម្លូតទារកក្នុងផ្ទៃក៏មិនត្រឹមត្រូវដូចគ្នាដែរ។

-ខ្ញុំមិនទាន់ចង់បានកូនទេ *«គ្មាននរណាម្នាក់អាចបង្ខំឲ្យទារកមកចាប់កំណើតក្នុងពិភពលោកនេះបានសោះឡើយ»* ។មនុស្សខ្លះមានយោបល់ថា ជារឿងមនុស្សធម៌ដែលសម្លាប់ទារក ជាជាងបណ្តោយឲ្យទារកកើតមកក្នុងពិភពលោកក្រោមឡេសថាមិនទាន់ចង់បានកូន។ ដូច្នេះ បើសិនជាខ្ញុំមិនចង់បានលោកអ្នក តើយើងអាចសម្លាប់លោកអ្នកចោល ដោយព្រោះតែការមិនចង់បានឬទេ? ឧបមាថា ក្មេងអាយុ២ឆ្នាំមិនត្រូវបានគេចង់បានទេ ហើយយើងជឿជាក់ថា ក្មេងនោះនឹងមានអាយុប្រាំឆ្នាំនៅពេលមួយ យើងក៏ដឹងថាក្មេងនោះនឹងត្រូវបានគេរំលោភបំពាន និងមិនយកចិត្តទុកដាក់ផង។ តើយើងនឹងសម្លាប់ក្មេងនោះនៅពេលនេះឬទេ ដើម្បីកុំឲ្យគេធ្វើបាបគាត់នៅពេលអនាគត? ទេ! គឺយើងប្រាកដជាព្យាយាមធ្វើឲ្យជីវិតក្មេងនោះកាន់តែប្រសើរណាឡើង។ ការចង់បាន មិនមែនជាលក្ខណៈវិនិច្ឆ័យអំពីសិទ្ធិមនុស្សនោះទេ គឺភាពជាមនុស្សឯណោះវិញដែលជាលក្ខណៈវិនិច្ឆ័យពិតប្រាកដ ឯបញ្ហានោះគឺថា *ទារកក្នុងផ្ទៃគឺជាមនុស្សពេញលក្ខណៈ* ។

-ការពិការភាព ***គ្មាននរណាម្នាក់ត្រូវបានបង្ខិតបង្ខំឲ្យចិញ្ចឹមកុមារដែលពិការភាពខាងរូបកាយ ឬសតិមិនល្អនោះទេ។*** ឧបមាថា ក្មេងអាយុពីរឆ្នាំមានសតិមិនគ្រប់។ ដោយព្រោះស្ថានភាពរបស់ក្មេងយ៉ាងដូច្នេះ តើច្បាប់សីលធម៌អនុញ្ញាតិឲ្យយើងសម្លាប់ក្មេងនោះឬទេ? គឺអត់ទេ។ គ្រប់គ្នាយល់ព្រមថាយើងត្រូវថែរក្សាក្មេងនោះ។ បើទារកក្នុងផ្ទៃដែលពិការជាមនុស្សពេញលក្ខណៈដូចក្មេងអាយុពីរឆ្នាំដែរនោះ ដូច្នេះសម្អាងលើច្បាប់សីលធម៌អ្វីយកមកយោងជារឿងត្រឹមត្រូវចំពោះការសម្លាប់ទារកក្នុងផ្ទៃ? ហេតុអ្វីបានជាម្នាក់មានសិទ្ធិរស់រានមានជីវិត ឯម្នាក់ទៀតគ្មានសិទ្ធនេះទៅវិញ? ដូច្នេះសូមបញ្ជាក់ម្តងទៀតថា *ទារកក្នុងផ្ទៃគឺជាមនុស្សពេញលក្ខណៈ* ។អ្នកខ្លះក៏ឲ្យយោបល់ថា *ជារឿងមនុស្សធម៌ដែលសម្លាប់ទារកក្នុងផ្ទៃដែលមានពិការភាព* ។ ប៉ុន្តែគេដឹងជាក់ក្នុងចិត្តថា មិនមែនជាមនុស្សធម៌ទេ តែផ្ទុយមកវិញ គឺគ្រួសារមិនចង់បន្ថែមការថែរក្សា ការចំណាយ និង ការអាម៉ាស។

-ស្ត្រីមានស្វ័យភាពលើរាងកាយរបស់ខ្លួន *«រាងកាយរបស់ខ្ញុំ ជម្រើសរបស់ខ្ញុំ!»* ។ ទេ! ពេលស្ត្រីម្នាក់និយាយថា ៖ រាងកាយរបស់ខ្ញុំ ជម្រើសរបស់ខ្ញុំ មានន័យថា នាងអាចជ្រើសរើសសម្លាប់ ហើយយកទារកចេញពីផ្ទៃរបស់នាងបាន គឺនាងយល់ខុសអំពីជីវវិទ្យា។ ទារកមិនមែនជាផ្នែកមួយនៃរាងកាយរបស់នាងឡើយ។ ទារកនោះជាបុគ្គលម្នាក់ផ្សេងទៀតដែលស្ថិតនៅក្នុងរាងកាយរបស់នាងជាបណ្តោះអាសន្ន។ ហេតុនេះហើយ នាងមិនអាចជ្រើសរើសធ្វើទុក្ខទោស ឬសម្លាប់បុគ្គលម្នាក់ផ្សេងទៀតនោះឡើយ ដូចគ្នាដែរ ម្តាយមិនអាចជ្រើសរើសធ្វើទុក្ខទោស ឬសម្លាប់កូនអាយុពីរឆ្នាំរបស់នាងបានឡើយ។ ទារកក្នុងផ្ទៃ និងជាទារក

ដែលបានកើតមក មានសិទ្ធិរស់រានមានជីវិតដូចគ្នា។ ស្ត្រីមានអំណាចដ៏អស្ចារ្យក្នុងការរក្សាទារកនោះ! (សំណួរទាក់ទងនឹងការមានកូនក្រៅស្បូន ត្រង់ចំណុចសំណួរទី២)។

**គ-បង្រៀនក្រុមជំនុំរបស់លោកអ្នក** - បដិសេធន៍ការរម្លូតកូន និងជួយសង្គ្រោះស្ត្រី និងទារកក្នុងផ្ទៃ
អ្នកដឹកនាំក្រុមជំនុំ និងគ្រូគង្វាល ត្រូវនាំពួកជំនុំឲ្យបដិសេធន៍ដាច់ខាតចំពោះការរម្លូតកូន និងចាត់ចែងឲ្យមានការជួយសង្គ្រោះស្ត្រី និងទារកក្នុងផ្ទៃពីទុក្ខទោសនៃការរម្លូត ក្នុងសហគមន៍ក្រៅក្រុមជំនុំដែលព្រះជាម្ចាស់បានឲ្យគេតាំងនៅ។

ត្រូវរៀបចំក្រុមជំនុំដោយលាតត្រដាងអំពើអាក្រក់នៃការរម្លូតកូន។ មនុស្សមួយចំនួនធំ ត្រូវមើលឲ្យឃើញពីចំណុចអយុត្តិធម៌ដោយផ្ទាល់ភ្នែកជាមុនសិន មុនពេលគេអាចបដិសេធការនោះបាន។ ផ្ទុយមកវិញ ភាពអយុត្តិធម៌ត្រូវបានគេបិទបាំង (ឬលាក់កំបាំង) ដើម្បីធ្វើការដោយសេរីភាព។ ការនៅស្ងៀមរបស់គ្រូគង្វាលអាចនាំពួកជំនុំឲ្យយល់ថា មិនអីទេ ការរម្លូតកូនដោយសម្ងាត់នោះ។ លោកប៉ូលមានប្រសាសន៍ថា ៖ «ហើយមិនត្រូវចូលរួមក្នុងការប្រព្រឹត្តអំពើឥតផលប្រយោជន៍ ដែលមកពីសេចក្តីងងឹតនោះឡើយ សូវបើកមុខអំពើទាំងនោះឲ្យគេឃើញ» (អេភេសូ ៥.១)។ ការនេះ ផ្តោតលើការរម្លូតកូនជាពិសេស។ ពេលការរម្លូតកូនត្រូវបានលាតដាង ភាពអយុត្តិធម៌ពិតត្រូវបានបើកសម្តែង ហើយមនុស្សស្ទើរទាំងអស់នឹងបដិសេធការពិតនោះ។

គ្រូគង្វាលមួយចំនួនចាប់ផ្តើមពីចំណុចខាងក្រោមនេះ ៖

១-លាតត្រដាងអំពើអាក្រក់នៃការរម្លូតកូន (អេភេសូ ៥.១១)។

២-ប្រកាសការលើកលែងទោសអំពើបាបនៃការរម្លូតកូន ដែលមានក្នុងអង្គព្រះគ្រិស្ត និង ព្រះលោហិតរបស់ព្រះអង្គ ដែលបានខ្ចាយ (អេសាយ ៥៣.៥, អេភេសូ ១.៧)។

៣-កោះហៅមនុស្សឲ្យមកទទួលសេរីភាព និងការជម្រះមនសិការពីភាពសៅហ្មងដោយសារជំនឿ (ហេព្រើ ១៣.១១)។

៤-អញ្ជើញបុរស និងស្ត្រីឲ្យចែកចាយទីបន្ទាល់ក្នុងក្រុមជំនុំ (វិវរណៈ ១២.១១)។

៥-បង្វឹកពួកគាត់ឲ្យចែកចាយពីមូលហេតុនៃការការពារជីវិតមនុស្សជារឿងសំខាន់ (សុភាសិត ៣១.៨-៩)។

៦-ចលនាក្រុមជំនុំឲ្យជួយសង្គ្រោះស្ត្រីមានវិបត្តិក្នុងសហគមន៍របស់លោកអ្នកដោយការតម្រង់ទិស និងអនុវត្តជំនួយសង្គ្រោះជីវិត (សុភាសិត ២៤.១០-១២, លូកា ១០.២៥-៣៧)។

**ការអនុវត្ត** ៖ «ជារឿងដ៏សំខាន់ណាស់ដែលត្រូវស្តាប់ព្រះបន្ទូល ធ្វើតាមព្រះបន្ទូល និងចែកចាយព្រះបន្ទូលដល់អ្នកឯទៀតៗ»។ សូមពិចារណាពីមនុស្សណាដែលលោកអ្នកអាចនឹងបង្ហាត់បង្រៀនបាន ឬអាចបង្រៀនដល់មិត្តភក្តិបានតែប្រាំនាក់ក៏ល្អដែរ។ តើលោកអ្នកអាចបង្រៀនអ្នកជិតខាងលោកអ្នក ក្រុមបុរស និង ក្រុមស្ត្រីរបស់លោកបានទេ? បើលោកអ្នកជាគ្រូគង្វាល តើលោកអ្នកអាចបង្រៀនគ្រូគង្វាលដែលអ្នកស្គាល់ទាំងអស់ក្នុងតំបន់លោកអ្នកបានទេ?

---

# ឯកសារយោង និង តំណរភ្ជាប់

ខណ:លោកអ្នកចាប់ផ្តើមបម្រើ លោកអ្នកអាចស្វែងរកសម្ភារ:ជំនួយដើម្បីបំពាក់បំប៉នលោកអ្នក និង ក្រុមរបស់លោកអ្នកសូមស្កេកូដ QR សម្រាប់មេរៀនដែលលោកអ្នកចង់បាន ឬទាញយកពីគេហទំព័រ www.baovemamsong.org ។

១-អន្តរាគមន៍វិបត្តិស្រ្តីមានផ្ទៃកម្រិតបឋម/ Pregnancy Crisis Intervention for beginners.
២-ប្រាំពីរជំហ៊ានដើម្បីចាប់ផ្តើមក្រុមជួយស្រ្តីមានផ្ទៃពោះ/7 Steps to start a Pregnancy Help Team.
៣-បញ្ហាតែមួយគត់ -ការចែករំលែកក្នុងវប្បធម៌លោកិយ / Only One Issue – sharing in a secular culture.
៤-មគ្គុទេសន៍អ្នកដឹកនាំ -ការបង្រៀនសំណួរទាំងបួន (មានទាំងកិច្ចការផង)/The Leader’s Guide – to teach the 4 Questions (includes worksheets).
៥-ការលើកលែងទោស និង ការដោះឲ្យមានសេរីភាព - ការប្រោសឲ្យជាក្រោយការរម្លូតកូន/ Forgiven and Set Free – post-abortion healing.

| | | | | |
|---|---|---|---|---|
| 1 - Pregnancy Crisis Intervention | 2 - 7 Steps to Start a Pregnancy Help Team | 3 - Only One Issue | 4 - Leaders Guide | 5 - Forgiven and Set Free |

---

**ត្រូវការជំនួយមែនទេ? មានផ្ទៃពោះមែនទេ?សូមទូរស័ព្ទទៅកាន់លេខ** 081 511 4526
សូមទាក់ទងយើងតាមសារអេឡិកត្រូនិកតាមអាយដ្ឋាន :
baovemamsong@gmail.com
សូមចូលមើលគេហទំព័រ www.baovemamsong.org ឬស្កេនកូន QR ។
ថ្នាក់ហ្វឹកហ្វឺនសំណួរបួនប្រការ និពន្ធដោយលោកគ្រូគង្វាល ចន អ៊ែនសឺរ ស្ថាបនិក និងប្រធានអង្គការសម្ព័ន្ធជីវិត(PassionLife Fellowship) តាមរយ:គេហទំព័រ:
https://www.passionlife.org/